តម្លាភាពកម្ពុជា

TRANSPARENCY INTERNATIONAL Cambodia



# អំពើពុករលួយ និងប្រព័ន្ធអភិបាលកិច្ច ប្រទេសកម្ពុជា

## ត្រូវធ្វើកំណែទម្រង់ទើបជាការប្រសើរ

ការវាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិ ២០១៤

របាយការណ៍សង្ខេប

# អង្គការតម្លាភាពកម្ពុជា

ផ្ទះលេខ៣ ផ្លូវលេខ ៣៩០ សង្កាត់បឹងកេងកង៣
ខណ្ឌចំការមន, ១២៣០៤, រាជធានីភ្នំពេញ
ទូរសព្ទ: (+៨៥៥) ២៣ ២១៤ ៤៣០ / (+៨៥៥) ២៣ ២១៤ ២១១

info@ticambodia.org
www.ticambodia.org
www.facebook.com/ticambodia
www.twitter.com/ticambodia

© រូបថតក្របមុខ៖ "ខ្ញុំចង់ក្លាយជាមនុស្សម្នាក់ក្នុងចំណោមពួកគាត់" ដោយ ភឹម កាន្និកា ជ័យលាភីការប្រកួតប្រជែងរូបថត ឆ្នាំ ២០១៤ របស់អង្គការតម្លាភាពកម្ពុជា។ រូបថតនេះ "បង្ហាញពីរបៀបដែលអំពើពុករលួយមានផលប៉ះពាល់អវិជ្ជមានមកលើការរស់នៅរបស់យើង"។ ការអប់រំថ្នាក់បឋមសិក្សានៅក្នុងប្រទេសកម្ពុជា មិនត្រូវចំណាយប្រាក់ឡើយសម្រាប់កុមារគ្រប់រូប។ ប៉ុន្តែគ្រូបង្រៀនតែងព្យាយាមរកប្រាក់ក្រៅបន្ថែមពីលើប្រាក់បៀវត្សរ៍ទាបរបស់ពួកគាត់តាមរយៈការឲ្យសិស្សបង់ប្រាក់ក្រៅផ្លូវការ។ ផលប៉ះពាល់នៃអំពើពុករលួយបែបនេះបានជ្រាបចូលសង្គម ដោយធ្វើឲ្យប៉ះពាល់ដល់មនុស្សគ្រប់រូប។

ខ្លឹមសារទាំងឡាយនៅក្នុងការបោះពុម្ពផ្សាយនេះឆ្លុះបញ្ចាំងតែពីទស្សនៈរបស់អង្គការតម្លាភាពកម្ពុជាប៉ុណ្ណោះ។ មានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មានដែលមាននៅក្នុងរបាយការណ៍នេះ។ ព័ត៌មានទាំងអស់ ត្រូវបានជឿថាមានភាពត្រឹមត្រូវ គិតត្រឹមខែ ឧសភា ឆ្នាំ ២០១៤។ ទោះយ៉ាងណាក៏ដោយ អង្គការតម្លាភាពកម្ពុជា មិនអាចទទួលខុសត្រូវចំពោះផលវិបាកផ្សេងៗដែលបណ្តាលមកពីការប្រើប្រាស់របាយការណ៍នេះក្នុងគោលបំណងផ្សេង ឬក្នុងបរិបទផ្សេងឡើយ។

© ២០១៦ អង្គការតម្លាភាពអន្តរជាតិ។ រក្សាសិទ្ធិគ្រប់យ៉ាង។

Australian Aid

SWEDEN

អង្គការតម្លាភាពអន្តរជាតិ គឺជាអង្គការសង្គមស៊ីវិលអន្តរជាតិ ដែលដឹកនាំការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅលើពិភពលោក។ តាមរយៈអង្គការ សាខាចំនួនជាង១០០ នៅទូទាំងពិភពលោក និងលេខាធិការដ្ឋានអន្តរជាតិនៅទីក្រុងប៊ែរឡាំង យើងលើកកម្ពស់ការយល់ដឹង អំពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃអំពើពុករលួយ ហើយធ្វើការជាមួយដៃគូជារដ្ឋាភិបាល ក្រុមហ៊ុនអាជីវកម្ម និងសង្គមស៊ីវិលដើម្បីបង្កើត និងអនុវត្តន៍វិធានការ ដ៏មានប្រសិទ្ធភាព ដើម្បីដោះស្រាយអំពើពុករលួយ។

អង្គការតម្លាភាពកម្ពុជាជាសាខាជាតិ ដែលទទួលស្គាល់ជាផ្លូវការដោយ អង្គការតម្លាភាពអន្តរជាតិ។ គោលបំណងរបស់យើង គឺសហការរួមគ្នាជាមួយបុគ្គល និងស្ថាប័ននានានៅគ្រប់ជាន់ថ្នាក់ ដើម្បីលើកកម្ពស់សុចរិតភាព និងកាត់បន្ថយអំពើពុករលួយក្នុងប្រទេសកម្ពុជា។


**ប្រធានគម្រោង**
**និងអ្នកនិពន្ធនាំមុខ**
Elizabeth Johnson

**អ្នកនិពន្ធ**
Rebecca Hyde
Therese Rosenfeld

**អ្នកស្រាវជ្រាវ**
ភឿន សុខចាន់
ប៉ូច ពិសាល

# បុព្វកថា

អំពើពុករលួយ គឺជាបញ្ហាប្រឈមនិងជាឧបសគ្គដ៏ធំមួយចំពោះការចែករំលែកផលប្រយោជន៍ពីកំណើន សេដ្ឋកិច្ចប្រកបដោយភាពយុត្តិធម៌ និងសមធម៌ ក៏ដូចជាចំពោះការអភិវឌ្ឍទៅមុខនៃលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា។ យើងអាចចាត់ទុកអំពើពុករលួយថាជាជំងឺសង្គមមួយដែលរីករាលដាលជាលក្ខណៈប្រព័ន្ធទៅដល់រដ្ឋបាលសាធារណៈគ្រប់ជាន់ថ្នាក់។ អស់រយៈពេលជាយូរមកហើយ បាតុភូតពុករលួយនេះបានធ្វើឱ្យប្រជាជនកម្ពុជា និងជនបរទេសមួយចំនួនដែលកំពុងធ្វើជំនួញក្នុងប្រទេសនេះ ទទួលស្គាល់ថាអំពើពុករលួយ ជាមធ្យោបាយដើម្បីរស់នៅប្រចាំថ្ងៃនៅក្នុងប្រទេសកម្ពុជា។ ជាលទ្ធផល ពលរដ្ឋជាច្រើនបានក្លាយទៅជាជនរងគ្រោះដោយស្ម័គ្រចិត្ត។ អ្នកខ្លះគ្មានជម្រើសផ្សេងក្រៅពីចូលរួមក្នុងប្រព័ន្ធនេះ ខណៈពេលដែលអ្នកខ្លះទៀតថែមទាំងចេះរកវិធីពុករលួយឱ្យកាន់តែមានប្រសិទ្ធភាព និងទាញយកប្រយោជន៍ឱ្យបានកាន់តែច្រើនបំផុតតាមដែលអាចធ្វើទៅបានពីការប្រព្រឹត្តិខុសឆ្គងទាំងនោះ។

ទោះជាយ៉ាងនេះក្តី ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានឈានទៅរកដំណោះស្រាយចំពោះអំពើពុករលួយ ដែលជាការឆ្លើយតបទៅនឹងការទាមទារដែលចេះតែកើនឡើងជាលំដាប់។ ដោយហេតុថាអភិបាលកិច្ចល្អត្រូវបានដាក់ជាចំណុចប្រសព្វនៃយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ការប្រឆាំងអំពើពុករលួយក៏បានក្លាយទៅជាអាទិភាពចម្បងមួយ។ ការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយកាលពីឆ្នាំ ២០១០ និងការបង្កើតស្ថាប័នប្រឆាំងអំពើពុករលួយបន្ទាប់មកទៀតនោះ បានផ្តល់ឱកាសសម្រាប់ការផ្លាស់ប្តូរស្ថានភាពនេះទាំងស្រុង។ ដូចដែលមានជាភស្តុតាងបញ្ជាក់ស្រាប់ ក្នុងរយៈពេលពីរបីឆ្នាំកន្លងមកនេះឥរិយាបទរបស់ប្រជាពលរដ្ឋចំពោះអំពើពុករលួយ បានកែប្រែគួរឱ្យកត់សម្គាល់ ចេញពីទម្លាប់ទទួលយកថាអំពើពុករលួយជាមធ្យោបាយដើម្បីរស់ ទៅជាអ្នកប្រឆាំងនឹងប្រព័ន្ធពុករលួយដោយទាមទារយ៉ាងសម្បើមឱ្យរដ្ឋាភិបាល និងអ្នកនយោបាយទាំងឡាយប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយឱ្យបានខ្លាំងក្លាបំផុត។ ការផ្លាស់ប្តូរនេះត្រូវបានផ្ទៀងផ្ទាត់បញ្ជាក់យ៉ាងច្បាស់តាមរយៈការសិក្សាដោយផ្អែកលើភស្តុតាងជាក់ស្តែង និងតាមរយៈលទ្ធផលនៃការបោះឆ្នោតថ្នាក់ជាតិកាលពីឆ្នាំ ២០១៣ កន្លងទៅនេះ។

សម្រាប់ដំណើរឆ្ពោះទៅមុខ យើងប្រាកដណាស់ថា អំពើពុករលួយនឹងនៅតែជាអាទិភាពដ៏ចម្បងមួយនៅក្នុងរបៀបវារៈនៃកំណែទម្រង់របស់រដ្ឋាភិបាល និងនៅក្នុងការពិភាក្សានយោបាយនានា។ ដូច្នេះការវាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិនេះ គឺជាធាតុបញ្ចូលដ៏មានតម្លៃ ហើយសមស្របនឹងពេលវេលាសម្រាប់រដ្ឋាភិបាលកម្ពុជា អ្នកនយោបាយ អង្គការសង្គមស៊ីវិល វិស័យឯកជន សារព័ត៌មាន ដៃគូអភិវឌ្ឍន៍ និងសមាជិកសង្គមទាំងមូលមើលឃើញទិដ្ឋភាពទាំងស្រុងនៃចន្លោះប្រហោងទាំងឡាយនៃប្រព័ន្ធសុចរិតភាពបច្ចុប្បន្ននៅក្នុងចំណោមស្ថាប័នគន្លឹះមួយចំនួននៅប្រទេសកម្ពុជា និងរិះរកវិធីសាស្ត្រដើម្បីបំពេញបន្ថែមលើចំនុចខ្វះខាតទាំងនោះ ដោយប្រើប្រាស់ចំណេះដឹង និងអំណះអំណាងទាំងឡាយចេញពីការវាយតម្លៃនេះ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុក

រលួយឱ្យកាន់តែមានប្រសិទ្ធភាពខ្លាំងជាងមុន។ ដោយសារតែខ្ញុំចាត់ទុកថា អំពើពុករលួយគឺជាជំងឺសង្គម ខ្ញុំយល់ថាការវាយតម្លៃជារួមនេះគឺជាការធ្វើរោគវិនិច្ឆ័យដ៏ពិស្ដារមួយដើម្បីស្វែងយល់ពីសារជាតិ និងមូលហេតុនៃជំងឺនេះ។ ដូច្នោះហើយ កម្រងអនុសាសន៍ដែលបានផ្ដល់ជូននៅក្នុងរបាយការណ៍វាយតម្លៃនេះ អាចជាវេជ្ជបញ្ជាសម្រាប់ការព្យាបាលជំងឺសង្គមមួយនេះ។

ជំនួសមុខឱ្យក្រុមការងារនៃអង្គការតម្លាភាពកម្ពុជា ខ្ញុំសូមទទួលស្គាល់ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមដ៏មានតម្លៃពីក្រុមការងារស្រាវជ្រាវ ដែលបានខិតខំធ្វើការយ៉ាងច្រើនក្នុងការរៀបចំរបាយការណ៍នេះឡើង ក៏ដូចជា ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ដែលបានចូលរួមក្នុងការវាយតម្លៃនេះ។ របាយការណ៍វាយតម្លៃនេះ បានធ្វើឡើងដោយមានការចូលរួមមតិ និងយោបល់ជំនាញពីភាគីពាក់ព័ន្ធទាំងអស់ ដែលរួមមានស្ថាប័នរដ្ឋាភិបាល សភាជាតិទាំងពីរ គណបក្សនយោបាយ អង្គការសង្គមស៊ីវិល វិស័យឯកជន សារព័ត៌មាន ដៃគូអភិវឌ្ឍន៍ និងអ្នកវិភាគឯករាជ្យ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះលេខាធិការដ្ឋាននៃអង្គការតម្លាភាពអន្តរជាតិនៅឯទីក្រុងប៊ែឡាំង ប្រទេសអាល្លឺម៉ង់ សម្រាប់មតិនិងយោបល់ផ្សេងៗអំពីវិធីសាស្ត្រ បែបផែនដាក់លាក់មួយនៃលំហូរព័ត៌មាន និងទម្រង់គ្រោងនៃការវាយតម្លៃនៃរបាយការណ៍នេះផ្ទាល់តែម្ដង។ ជាពិសេស ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមប្រឹក្សាភិបាលនៃអង្គការតម្លាភាពកម្ពុជា និងក្រុមប្រឹក្សាយោបល់សម្រាប់ការសិក្សានេះ ចំពោះការដឹកនាំ មគ្គុទ្ទេសក៍ និងការចូលរួមរបស់ពួកគាត់ក្នុងដំណើរការរៀបចំរបាយការណ៍ដ៏សំខាន់មួយនេះ។

ជាចុងក្រោយ ហើយក៏សំខាន់ណាស់ដែរនោះ ខ្ញុំសូមស្នើសុំការគាំទ្រ និងកិច្ចសហការណ៍របស់ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ដើម្បីធានាថារាល់អនុសាសន៍ទាំងអស់ដែលបានស្នើឡើងនៅក្នុងរបាយការណ៍នេះ ត្រូវបានអនុវត្តក្នុងគោលបំណងជំរុញឱ្យមានការពង្រឹងស្ថាប័នគន្លឹះទាំងឡាយ ព្រមទាំងប្រព័ន្ធសុចរិតភាពទាំងមូល និងដើម្បីឱ្យកិច្ចខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើពុករលួយរបស់យើងកាន់តែមានប្រសិទ្ធភាពជាងមុន ដែលអាចនាំឱ្យមានដំណើរឆ្ពោះទៅមុខដ៏រុងរឿងជាមួយនឹងលទ្ធផលល្អៗ ដែលមិនអាចត្រឡប់មកជាអាក្រក់វិញបាន សម្រាប់ថ្ងៃអនាគតតទៅមុខទៀត។ ■



**ព្រាប កុល**

នាយកប្រតិបត្តិ

អង្គការតម្លាភាពកម្ពុជា

# មាតិកា


**បុព្វកថា** ........ ៦

**I. អំពីសង្ខេបរបាយការណ៍វាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិ** ........ ១០

**II. ប្រព័ន្ធសុចរិតភាពថ្នាក់ជាតិ**

១. អង្គនីតិប្បញ្ញត្តិ ........ ១២

២. អង្គនីតិប្រតិបត្តិ ........ ១៤

៣. ស្ថាប័នតុលាការ ........ ១៦

៤. វិស័យសាធារណៈ ........ ១៨

៥. ទីភ្នាក់ងារអនុវត្តន៍ច្បាប់ ........ ២០

៦. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ........ ២២

៧. ការិយាល័យប្រជាពលរដ្ឋ ........ ២៤

៨. អាជ្ញាធរសវនកម្មជាតិ ........ ២៦

៩. ស្ថាប័នប្រឆាំងអំពើពុករលួយ ........ ២៨

១០. គណបក្សនយោបាយ ........ ៣០

១១. ប្រព័ន្ធផ្សព្វផ្សាយ ........ ៣២

១២. សង្គមស៊ីវិល ........ ៣៤

១៣. វិស័យអាជីវកម្ម ........ ៣៦

**III. សេចក្តីសន្និដ្ឋាន** ........ ៣៨

# អំពីសង្ខេបរបាយការណ៍វាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិ

កូនសៀវភៅដែលលោកអ្នកកំពុងកាន់ក្នុងដៃនេះ គឺជាសេចក្តីសង្ខេបនៃរបាយការណ៍វាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិរបស់ប្រទេសកម្ពុជា។ ការវាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិគឺជាការសិក្សាអំពីលក្ខណៈនៃប្រព័ន្ធអភិបាលកិច្ចរបស់ប្រទេសមួយ។ ការសិក្សានេះបានធ្វើឡើងនៅក្នុងប្រទេសជាង ១០០ រួមទាំងកម្ពុជាផង ដោយផ្អែកលើវិធីសាស្ត្រស្រាវជ្រាវដែលបង្កើតឡើងនៅឯលេខាធិការដ្ឋាននៃអង្គការតម្លាភាពអន្តរជាតិ ប្រចាំនៅទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់។

ការសិក្សានេះ វាយតម្លៃកម្រិតនៃអំពើពុករលួយ និងប្រសិទ្ធភាពនៃយន្តការប្រឆាំងអំពើពុករលួយក្នុងពេលបច្ចុប្បន្ននៅក្នុងប្រទេសមួយដោយពិនិត្យមើលទៅលើវិស័យមួយចំនួន ហើយផ្តល់នូវការវិភាគមួយយ៉ាងល្អិតល្អន់ រួមមានសមត្ថភាព អភិបាលកិច្ច តួនាទី ព្រមទាំងអនុសាសន៍គោលនយោបាយគន្លឹះៗផ្អែកទៅលើការអនុវត្តល្អបំផុត។

ការវាយតម្លៃនេះ ផ្តោតលើស្ថាប័នអភិបាលកិច្ចស្នូល (ឬហៅថាស្ថាប័នគ្រឹះ) ចំនួន ១៣ ដែលត្រូវ



បានចាត់ទុកថាជាស្ថាប័នសំខាន់ចាំបាច់សម្រាប់លើកកម្ពស់ប្រព័ន្ធសុចរិតភាពឱ្យបានរឹងមាំ។ ស្ថាប័នគ្រឹះទាំងនេះរួមមាន៖ អង្គនីតិប្បញ្ញត្តិ អង្គនីតិប្រតិបត្តិ ស្ថាប័នតុលាការ វិស័យសាធារណៈ ទីភ្នាក់ងារអនុវត្តន៍ច្បាប់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ការិយាល័យប្រជាពលរដ្ឋ អាជ្ញាធរសវនកម្មជាតិ ស្ថាប័នប្រឆាំងអំពើពុករលួយ គណបក្សនយោបាយ ប្រព័ន្ធផ្សព្វផ្សាយ សង្គមស៊ីវិល និងវិស័យអាជីវកម្ម។

## វិធីសាស្ត្រសិក្សា

ក្រុមស្រាវជ្រាវរបស់អង្គការតម្លាភាពកម្ពុជាទទួលខុសត្រូវប្រមូលទិន្នន័យ និងធ្វើសេចក្តីព្រាងរបាយការណ៍តាមបែបគុណវិស័យ ព្រមទាំងផ្តល់យោបល់អំពីការដាក់ពិន្ទុដំបូង។ អ្នកស្រាវជ្រាវពឹងផ្អែកលើប្រភពផ្តល់ព័ត៌មានជាច្រើន រួមមាន៖ កិច្ចសម្ភាស របាយការណ៍ កាសែត សៀវភៅ អត្ថបទទិនានុប្បវត្តិ ច្បាប់ និងបទបញ្ញត្តក្នុងប្រទេស ច្បាប់អន្តរជាតិ និងប្រភពព័ត៌មានតាមអ៊ីនធើណិត។ ផ្នែកនីមួយៗនៃរបាយការណ៍នេះត្រូវបានបញ្ជូនទៅកាន់លេខាធិការដ្ឋានរបស់អង្គការតម្លាភាពអន្តរជាតិនៅទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់ ដើម្បីធ្វើការត្រួតពិនិត្យជានាគុណភាព។ នៅពេលដែលមតិយោបល់របស់លេខាធិការដ្ឋានបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងរបាយការណ៍ដែលបានរៀបចំឡើងដោយក្រុមស្រាវជ្រាវរបស់អង្គការតម្លាភាពកម្ពុជារួចហើយរបាយការណ៍នេះក៏បានត្រូវបញ្ជូនទៅគណៈកម្មាធិការគ្រប់គ្រងជាន់ខ្ពស់របស់អង្គការតម្លាភាពកម្ពុជា និងក្រុមប្រឹក្សាយោបល់សម្រាប់ការសិក្សាមួយនេះ ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញ។

ក្រុមប្រឹក្សាយោបល់មានសមាសភាពអ្នកជំនាញចំនួន ១៣រូប មកពីស្ថាប័នរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ វិស័យអាជីវកម្ម ស្ថាប័នអប់រំជាន់ខ្ពស់ សង្គមស៊ីវិល និងសហគមន៍ម្ចាស់ជំនួយនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀត អង្គការតម្លាភាពកម្ពុជា បានរៀបចំសិក្ខាសាលាស្តីពីសុចរិតភាពថ្នាក់ជាតិនៅខែ វិច្ឆិកា ឆ្នាំ២០១៣ ដោយបានអញ្ជើញភាគីពាក់ព័ន្ធនានាដែលប្រឆាំងអំពើពុករលួយ និងអ្នកជំនាញផ្នែកស្ថាប័នជាច្រើននាក់ ដើម្បីចូលរួមពិភាក្សា និងត្រួតពិនិត្យសេចក្តីព្រាងរបាយការណ៍នេះ ក៏ដូចជាបង្កើតអនុសាសន៍គោលនយោបាយ ដោយផ្អែកលើលទ្ធផលនៃការសិក្សានេះ។

## វិសាលភាពនៃរបាយការណ៍

ការវាយតម្លៃនេះ ឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធអភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា ដោយពឹងផ្អែកជាចម្បងលើប្រភពព័ត៌មាននានានៅចន្លោះពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០១៤។ អង្គការតម្លាភាពកម្ពុជាធានាថា លទ្ធផលនៃរបាយការណ៍ដែលមានលក្ខណៈ រឹងមាំនេះអាចប្រើប្រាស់បានជាមូលដ្ឋានដើម្បីផ្តល់អនុសាសន៍ស្តីពីគោលនយោបាយ។ អ្វីទាំងអស់នេះ គឺមានគោលបំណងលើកកម្ពស់ប្រព័ន្ធអភិបាលកិច្ចឲ្យបានកាន់តែល្អប្រសើរឡើង និងជំរុញឲ្យមានការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា។ ■

# ១ អង្គនីតិប្បញ្ញត្តិ

## ១.១. សមត្ថភាព

ក្នុងក្របខ័ណ្ឌច្បាប់ មានបទប្បញ្ញត្តិមួយចំនួន ដើម្បីធានាថា អង្គនីតិប្បញ្ញត្តិទទួលបាន ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានភស្តុភារ ចាំបាច់ ដើម្បីអនុវត្តន៍មុខងាររបស់ខ្លួន នៅក្នុងការអនុវត្តជាក់ស្តែង។ ប្រាក់ឧបត្ថម្ភសម្រាប់អ្នកធ្វើច្បាប់ ក៏ដូចជាថវិកាស្វយ័តសម្រាប់ទាំងរដ្ឋសភា ទាំងព្រឹទ្ធសភា មានការធានាដោយរដ្ឋធម្មនុញ្ញ។ ប៉ុន្តែពុំមានការលើកឡើងអំពីចំនួនអប្បបរមាទាក់ទងនឹងទំហំថវិកានិងប្រាក់ឧបត្ថម្ភឡើយ។

ក្រោយពីរដ្ឋាភិបាលបានអនុម័តហើយ ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបញ្ជូនទៅរដ្ឋសភា នៅសប្តាហ៍ទីមួយនៃខែវិច្ឆិកា ដើម្បីត្រួតពិនិត្យ និងអនុម័ត។ នៅសប្តាហ៍ទីមួយនៃខែធ្នូ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបញ្ជូនទៅព្រឹទ្ធសភាពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី២៥ ខែធ្នូ នៃឆ្នាំនីមួយៗ។ តាមរយៈតារាងពេលវេលានេះ ទាំងរដ្ឋសភា ទាំងព្រឹទ្ធសភា មានពេលតែប៉ុន្មានសប្តាហ៍ប៉ុណ្ណោះដើម្បីត្រួតពិនិត្យថវិកា បន្ទាប់ពីសេចក្តីព្រាងច្បាប់ថវិកានេះត្រូវបានអនុម័តដោយរដ្ឋាភិបាលរួចហើយ។

ប្រការនេះ អាចកម្រិតនូវលទ្ធភាពរបស់សមាជិកសភា ក្នុងការត្រួតពិនិត្យមើលឱ្យបានគ្រប់គ្រាន់ទៅលើថវិកា ដើម្បីធានាថាធនធានសាធារណៈត្រូវបានបែងចែងយ៉ាងសមរម្យ។

អង្គនីតិប្បញ្ញត្តិមានធនធានដែលអាចឱ្យខ្លួនបំពេញមុខងារបានក្នុងកម្រិតមួយ។

## ១.២. អភិបាលកិច្ច

មានបទប្បញ្ញត្តិតិចតួចប៉ុណ្ណោះដែលធានាថា សាធារណជនអាចចេញចូលក្នុងស្ថាប័នទៅកាន់អង្គនីតិប្បញ្ញត្តិបាន និងទទួលបានព័ត៌មានពាក់ព័ន្ធនឹងការចាត់ចែង និងមុខងាររបស់ស្ថាប័ននេះ។ រដ្ឋធម្មនុញ្ញ ចែងថា សម័យប្រជុំរបស់រដ្ឋសភា និងព្រឹទ្ធសភាត្រូវធ្វើឡើងជាសាធារណៈ ប៉ុន្តែចំណុចនេះមានន័យយ៉ាងណានោះមិនមានការពន្យល់ឡើយ។

ចំណុចជាច្រើនទាក់ទងនឹងតម្លាភាពរបស់អង្គនីតិប្បញ្ញត្តិ មិនមានការបញ្ជាក់ឱ្យបានច្បាស់លាស់ទេ នៅក្នុងរដ្ឋធម្មនុញ្ញ។ ការទទួលបានព័ត៌មានពីឯកសារផ្លូវការរបស់អង្គនីតិប្បញ្ញត្តិមានកម្រិតនៅឡើយ ដោយសារមិនទាន់មានការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន។

អង្គនីតិប្បញ្ញត្តិមានភាពមិនច្បាស់លាស់ភាគច្រើន។ សាធារណជនទទួលបានព័ត៌មានពាក់ព័ន្ធនៅមានកម្រិតអំពីដំណើរការប្រព្រឹត្តិទៅការធ្វើសេចក្តីសម្រេច និងទាក់ទងនឹងហិរញ្ញវត្ថុរបស់ស្ថាប័ននេះ។

រដ្ឋសភា និងព្រឹទ្ធសភា មានគេហទំព័រដែលមានចុះផ្សាយព័ត៌មានអំពីរចនាសម្ព័ន្ធច្បាប់ សេចក្តីប្រកាសព័ត៌មាន និងសកម្មភាពការងារ។ គេហទំព័រនេះ មានតែព័ត៌មានសម្រាំងមួយចំនួនតែប៉ុណ្ណោះ អត្ថបទខ្លីៗ និងរូបភាពអំពីកិច្ចប្រជុំផ្លូវការ និងការចុះហត្ថលេខា មិនមានឃើញការពិភាក្សាវែកញែករបស់អង្គនីតិប្បញ្ញត្តិ ចំពោះហិរញ្ញវត្ថុ សេចក្តីព្រាងច្បាប់ និងការពន្យល់ហេតុផលអំពីសកម្មភាពរបស់អង្គនីតិប្បញ្ញត្តិ ។

ទោះបីការផ្សាយអំពីការពិភាក្សាវែកញែករបស់សភាមានការចាក់ផ្សាយតាមទូរទស្សន៍ជាតិក៏ដោយចុះ ក៏ទូរទស្សន៍នេះស្ថិតនៅក្រោម

ការគ្រប់គ្រងរបស់រដ្ឋាភិបាល។ ព័ត៌មានផ្សាយនៅមានកម្រិតតិច ដោយសារតែរចនាសម្ព័ន្ធនៃការប្រជុំសភា ក្នុងកំឡុងពេលពិភាក្សាសភាមានការបែងចែកជាក្រុមដោយមានគ្នា១០នាក់ ក្រុមនីមួយៗមានពេល ២០នាទីសម្រាប់និយាយ ក្រុមនីមួយៗនិយាយឱ្យតំណាងក្រុមទាំងមូល គឺមិនតាងនាមឱ្យបុគ្គលម្នាក់ៗទេ។

## ១.៣. តួនាទី

មានបទប្បញ្ញត្តិមួយចំនួនអាចឱ្យអង្គនីតិប្បញ្ញត្តិត្រួតពិនិត្យអង្គនីតិប្រតិបត្តិ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង សមត្ថភាពរបស់អង្គនីតិប្បញ្ញត្តិក្នុងការអនុវត្តការងារនេះនៅមានកម្រិតយ៉ាងខ្លាំង។

ភារកិច្ចរបស់សមាជិកសភាក្នុងការត្រួតពិនិត្យអង្គនីតិប្រតិបត្តិមានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ។ ក្នុងនោះរួមមានការដាក់សំណួរទៅរដ្ឋាភិបាល ការត្រួតពិនិត្យការបំពេញការងាររបស់រដ្ឋាភិបាល ការស្នើសុំការបំភ្លឺអំពីបញ្ហាពិសេសផ្សេងៗ និងការកោះអញ្ជើញរដ្ឋមន្ត្រីឱ្យមកបំភ្លឺអំពីបញ្ហាណាមួយក្នុងការទទួលខុសត្រូវរបស់ខ្លួន។

នៅក្នុងការអនុវត្តជាក់ស្តែង សមត្ថភាពឯករាជ្យរបស់អង្គនីតិប្បញ្ញត្តិក្នុងការត្រួតពិនិត្យអង្គនីតិប្រតិបត្តិ ត្រូវបានរាំងស្ទះដោយសារថាឯករាជ្យភាពរបស់អង្គនីតិប្បញ្ញត្តិនៅមានកម្រិតគួរឱ្យកត់សម្គាល់។

## ១.៤. អនុសាសន៍

- របាយការណ៍ស្តីពីកិច្ចប្រជុំរដ្ឋសភាទាំងអស់ត្រូវតែរៀបចំធ្វើហើយធ្វើយ៉ាងណាឱ្យសាធារណជនអាចមើលបាន។
- ធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងរើសតំណាងរាស្ត្រ(ជំពូក៥) ដើម្បីឱ្យមានប្បញ្ញត្តិចែងថា តំណែងជាសមាជិកសភាមិនត្រូវពឹងផ្អែកលើសមាជិកភាពនៅក្នុងគណបក្សនយោបាយណាមួយឡើយ។ បុគ្គលអាចឈរឈ្មោះតំណាងរាស្ត្រឯករាជ្យបាន ដូច្នេះតំណែងសមាជិកសភារបស់អ្នកតំណាងរាស្ត្រនោះគាត់មិនបានបាត់បង់ឡើយ បើទោះបីជាគាត់បាត់បង់តំណែងនៅក្នុងបក្សក៏ដោយ។
- ធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់អំពីរបៀបបង្កើតរដ្ឋសភា។ មាត្រា៦ ចែងថារដ្ឋសភាត្រូវមានយ៉ាងតិច១២០អាសនៈ។
- លុបបំបាត់ការអនុវត្តការបោះឆ្នោតដោយលើកដៃនៅរដ្ឋសភា និងព្រឹទ្ធសភា។ ប្រអប់ឆ្នោតសម្ងាត់ត្រូវដាក់ឡើងវិញ ហើយរាល់ការបោះឆ្នោតត្រូវធ្វើឡើងដោយសម្ងាត់។
- បង្កើតនីតិវិធីច្បាប់ច្បាស់លាស់ដែលចែងថារាល់សេចក្តីព្រាងច្បាប់ទាំងអស់ គួរឱ្យមានជាសាធារណៈ ដើម្បីឱ្យមានការពិនិត្យមើលមុនពេលអនុម័ត។
- ធានាថាកូតាជាប់កាតព្វកិច្ចត្រូវមានស្ត្រីយ៉ាងតិច៣០ភាគរយ នៅក្នុងបញ្ជីបេក្ខជនត្រូវអនុវត្តនៅមុនពេលបោះឆ្នោតណាមួយ ដើម្បីជម្រុញឱ្យមានតំណាងជាស្ត្រីនៅក្នុងនយបាយ។
- តម្កើងមាត្រា៨០ នៃរដ្ឋធម្មនុញ្ញដែលការពារអភ័យឯកសិទ្ធិ និងចែងថា "តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវ បានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុសម្តែងយោបល់ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ"។ ប្រសិនបើតំណាងរាស្ត្រត្រូវគេចោទប្រកាន់ការបោះឆ្នោតត្រូវធ្វើឡើងនៅរដ្ឋសភា តាមរយៈការបោះឆ្នោតដោយសម្ងាត់។ ■

# ២ អង្គនីតិប្រតិបត្តិ

## ២.១. សមត្ថភាព

អង្គនីតិប្រតិបត្តិមានធនធានមួយចំនួន ប៉ុន្តែកម្រិត ប្រាក់បៀវត្សរ៍ទាប និងសមត្ថភាពធនធានមនុស្ស មិនគ្រប់គ្រាន់ធ្វើឱ្យប្រសិទ្ធភាពការងារ និងវិជ្ជាជីវៈ របស់អង្គនីតិប្រតិបត្តិនៅមានកម្រិត។ ថវិកា របស់អង្គនីតិប្រតិបត្តិដាក់បញ្ចូលទៅក្នុងកញ្ចប់ ថវិកាជាតិប្រចាំឆ្នាំ ហើយមានការបែងចែកច្បាស់ លាស់អំពីការបែងចែកថវិកាប្រចាំឆ្នាំសម្រាប់គណៈ រដ្ឋមន្ត្រី។ ធនធានហិរញ្ញវត្ថុគណៈរដ្ឋមន្ត្រីកើន ឡើងហួសពីតួលេខថវិកាផ្លូវការរបស់រដ្ឋាភិបាល។ កម្ពុជានៅតែពឹងផ្អែកលើជំនួយ ដោយទទួល ជំនួយចំនួនប្រហែល ១ពាន់លានដុល្លារក្នុង មួយឆ្នាំ។ ជាក់ស្តែងកន្លងមកអង្គនីតិប្រតិបត្តិបាន ទទួលជំនួយពីសាធារណរដ្ឋប្រជាមានិតចិន នូវ អគារដ៏ធំមួយផ្តល់ដល់គណៈរដ្ឋមន្ត្រីដែលមាន តម្លៃ៤៩លានដុល្លារ។

អង្គនីតិប្រតិបត្តិត្រូវបានរដ្ឋធម្មនុញ្ញធានាថា មានឯករាជ្យភាពកម្រិតខ្ពស់គ្មានការជ្រៀតជ្រែក ពីខាងក្រៅ។ អង្គនីតិប្រតិបត្តិទទួលបានឯករាជ្យ ភាពខ្ពស់នៅក្នុងតួនាទី និងមុខងាររបស់ខ្លួន។ រដ្ឋធម្មនុញ្ញបានចែងថា សមាជិករដ្ឋាភិបាលមាន ការទទួលខុសត្រូវជារួមចំពោះគោលនយោបាយ រួមរបស់រដ្ឋាភិបាល។ ក្រៅពីនេះ នាយករដ្ឋមន្ត្រី គ្រប់គ្រងកិច្ចការរបស់គណៈរដ្ឋមន្ត្រី និងធ្វើជា ប្រធានកិច្ចប្រជុំពេញអង្គប្រចាំសប្តាហ៍របស់ គណៈមន្ត្រី ។

តួអង្គដទៃទៀតខ្សោយក្នុងការជ្រៀតជ្រែកចូលក្នុង សកម្មភាព និងការសម្រេចចិត្តរបស់អង្គនីតិ ប្រតិបត្តិ។ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់របស់រដ្ឋាភិបាល ពុំមានភាពគ្មានឯករាជ្យពីគណបក្សប្រជាជនដែល កំពុងគ្រប់គ្រងប្រទេសឡើយ។ ស្ថាប័នអភិបាល កិច្ចសំខាន់ទាំងបីត្រូវបានរៀបចំតាមខ្សែបណ្តាញ បក្សពួក។ គណបក្សគ្រប់គ្រងប្រទេស មាន អភិបាលកិច្ចតាមខ្សែរយៈយ៉ាងរឹងមាំពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ។

## ២.២. អភិបាលកិច្ច

មានបទបញ្ញាមួយចំនួនតូចដែលអាចឱ្យសាធារណ ជនទទួលបានព័ត៌មានអំពីសកម្មភាពពាក់ព័ន្ធ របស់អង្គនីតិប្រតិបត្តិ។ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញ វត្ថុសាធារណៈឆ្នាំ២០០៨ មាត្រា៨៤ តម្រូវថា រាល់កំណត់ហេតុ និងចំណាយរបស់រដ្ឋបាលជាតិ ត្រូវតែមានតម្លាភាព និងមានជាសាធារណៈ។ ដូច្នេះ ច្បាប់នេះបញ្ជាក់ថាព័ត៌មានហិរញ្ញវត្ថុរបស់ អង្គនីតិប្រតិបត្តិ គួរតែបើកចំហជាសាធារណៈ។

ដូចគ្នានឹងមន្ត្រីរាជការស៊ីវិលដែរ មន្ត្រីរដ្ឋា-ភិបាលត្រូវតែប្រកាសទ្រព្យសម្បត្តិរបស់ខ្លួនទៅ អង្គភាពប្រឆាំងអំពើពុករលួយរាល់ពីរឆ្នាំម្តង។ ប៉ុន្តែឯកសារទាំងនេះត្រូវរក្សាទុកជាការសម្ងាត់ ខ្ពស់បំផុត លើកលែងតែមានការស៊ើបអង្កេត។ ដូចនេះ គ្មានល័ក្ខខ័ណ្ឌតម្រូវផ្លូវច្បាប់ដែលធានា ថាការប្រកាសទ្រព្យរបស់អង្គនីតិប្រតិបត្តិត្រូវតែ ផ្សព្វផ្សាយឱ្យសាធារណជនដឹងឡើយ។

## ២.៣. តួនាទី

ការគ្រប់គ្រងវិស័យសាធារណៈ អង្គនីតិប្រតិបត្តិ សកម្មក្នុងកម្រិតមួយ ប៉ុន្តែចាំបាច់ត្រូវអភិវឌ្ឍន៍ បន្ថែមទៀត ដើម្បីធានាឱ្យមានវិស័យសាធារណៈ មួយដែលមានអភិបាលកិច្ចប្រកបដោយតម្លាភាព

គណនេយ្យភាព សុចរិតភាព និងមានការចូលរួមកម្រិតខ្ពស់។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានអភិវឌ្ឍន៍ដើម្បីពង្រឹងអភិបាលកិច្ចមូលដ្ឋាន និងលទ្ធិប្រជាធិបតេយ្យ។

មានកំណែទម្រង់មួយចំនួនដែលអង្គនីតិប្រតិបត្តិបានផ្តួចផ្តើម និងលើកកម្ពស់ដើម្បីប្រឆាំងអំពើពុករលួយ និងលើកកម្ពស់សុចរិតភាព។ ប៉ុន្តែភាពរីកចម្រើនមានជាបណ្តើរៗ ហើយប្បញ្ញត្តិពាក់ព័ន្ធនៅមានចន្លោះប្រហោង។

## ២.៤. អនុសាសន៍

អង្គនីតិប្រតិបត្តិ គួរពង្រឹងតម្លាភាព និងគណនេយ្យភាពរបស់ខ្លួន តាមវិធីដូចខាងក្រោម ដោយអនុលោមទៅតាមមាត្រា១៩ នៃគោលការណ៍ស្តីពីសេរីភាពព័ត៌មាន៖

- ធានាឱ្យមានការបោះពុម្ពផ្សាយជាសាធារណៈនូវរាល់ព័ត៌មានប្រតិបត្តិការទាំងអស់ដែលទាក់ទងនឹងមុខងាររបស់អង្គនីតិប្រតិបត្តិ រួមមានក្រសួង គណៈកម្មាធិការ និងអនុគណៈកម្មាធិការក្រសួងទាំងអស់ ដោយបោះពុម្ពផ្សាយលើក្រដាស និងជាទម្រង់ឯកសារអេឡិចត្រូនិក។ ការផ្សព្វផ្សាយនេះ រួមបញ្ចូលទាំងឯកសារនានាដែលពាក់ព័ន្ធនឹងរាល់នីតិវិធីផ្ទៃក្នុង ក្រមសីលធម៌ បញ្ជីឈ្មោះសមាជិកអង្គនីតិប្រតិបត្តិទាំងអស់ និងនីតិវិធីវិន័យរបស់អង្គនីតិប្រតិបត្តិ។
- បើកចំហជាសាធារណៈនូវរាល់របាយការណ៍ប្រចាំឆ្នាំ ឯកសារផ្លូវការ និងសេចក្តីលម្អិតអំពីការចំណាយរបស់អង្គនីតិប្រតិបត្តិ ដោយធ្វើការផ្សព្វផ្សាយជាទម្រង់ឯកសារអេឡិចត្រូនិកនៅលើគេហទំព័ររបស់រដ្ឋាភិបាល និងបោះពុម្ពលើក្រដាស។ របាយការណ៍ទាំងអស់ត្រូវតែអាចឱ្យសាធារណជនទទួលបាន ក្នុងរយៈពេលមួយឆ្នាំ ក្រោយសេចក្តីព្រាងចប់។
- ធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំអំពីចំណូលហិរញ្ញវត្ថុរបស់សមាជិកអង្គនីតិប្រតិបត្តិទាំងអស់ រួមមានបច្ចុប្បន្នភាពបញ្ជីប្រាក់បៀវត្សរ៍របស់អង្គនីតិប្រតិបត្តិ។ ធានាថាព័ត៌មានទាំងនេះអាចឱ្យសាធារណជនទទួលបានជាប្រភេទឯកសារអេឡិចត្រូនិក នៅលើគេហទំព័ររបស់រដ្ឋាភិបាល និងជាប្រភេទឯកសារបោះពុម្ពលើក្រដាស។ ព័ត៌មានទាំងអស់ ត្រូវតែអាចឱ្យសាធារណជនទទួលបាននៅក្នុងឆ្នាំសារពើពន្ធពាក់ព័ន្ធ។
- បង្កើនប្រាក់បៀវត្សរ៍គោលរបស់សមាជិកអង្គនីតិប្រតិបត្តិ ដើម្បីកាត់បន្ថយតម្រូវការត្រូវរកប្រាក់ចំណូលបន្ថែម ក្នុងរូបភាពជាអំពើសូកប៉ាន់ និងក្នុងរូបភាពផ្សេងទៀតដែលអាចបង្កើតឱ្យមានទំនាស់ផលប្រយោជន៍។
- បង្កើនការផ្សព្វផ្សាយ និងការអប់រំជាសាធារណៈអំពីច្បាប់នានារបស់ប្រទេសកម្ពុជា ដែលពន្យល់អំពីតួនាទីរបស់អង្គនីតិប្រតិបត្តិ និងការបែងចែងអំណាចដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ ■

# ៣ ស្ថាប័នតុលាការ

## ៣.១. សមត្ថភាព

មិនមានច្បាប់សំខាន់ដែលកំណត់ និងចែងអំពីប្រាក់បៀវត្សរ៍ ល័ក្ខខ័ណ្ឌការងារនិងការបែងចែកកញ្ចប់ថវិកាសម្រាប់ស្ថាប័នតុលាការនៅក្នុងប្រទេសកម្ពុជាឡើយ។ ស្ថានភាពជារួមនេះ នាំឱ្យស្ថាប័នតុលាការគ្មានប្រសិទ្ធភាព។ បច្ចុប្បន្ននេះ មានកង្វះខាតផ្នែកច្បាប់សំខាន់ និងស្របតាមស្តង់ដារអន្តរជាតិដែលចែងអំពីប្រាក់បៀវត្សរ៍ ល័ក្ខខ័ណ្ឌការងារ និងការបែងចែកថវិកានៅក្រសួងយុត្តិធម៌។ រដ្ឋធម្មនុញ្ញតម្រូវឱ្យមានការប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃអង្គចៅក្រម និងព្រះរាជអាជ្ញា។ ច្បាប់នេះត្រូវបានអនុម័តនៅក្នុងខែឧសភា ឆ្នាំ២០១៤ ក្រោមការតវ៉ាយ៉ាងខ្លាំងពីសំណាក់ភាគីពាក់ព័ន្ធ ជាពិសេសសង្គមស៊ីវិល។ ពួកគេបានលើកហេតុផលថាច្បាប់នេះមិនធានាឯករាជ្យពិតប្រាកដនៃតុលាការឡើយ។

ស្ថាប័នតុលាការខ្វះខាតធនធានហិរញ្ញវត្ថុធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធក្នុងកម្រិតខ្ពស់ដែលរារាំងដល់ស្ថាប័ននេះមិនឱ្យដំណើរការបានប្រកបដោយប្រសិទ្ធភាព។

តាមច្បាប់ស្ថាប័នតុលាការមានឯករាជ្យភាព។ ទោះបីជាឯករាជ្យភាពរបស់ស្ថាប័នតុលាការមានចែងនៅក្នុងរដ្ឋធម្មនុញ្ញក៏ដោយ ក៏ឯករាជ្យភាពនេះត្រូវបានប៉ះពាល់ដោយសារឥទ្ធិពលនៃអង្គនីតិប្រតិបត្តិទៅលើការតែងតាំងសមាសភាពគ្រប់គ្រងស្ថាប័នតុលាការ។ ការបែងចែកអំណាចឱ្យដាច់ដោយឡែករវាងអង្គនីតិប្រតិបត្តិ នីតិប្បញ្ញត្តិ និងតុលាការ នៅក្នុងប្រទេសកម្ពុជាត្រូវបានធានាដោយមាត្រា១៣០ នៃរដ្ឋធម្មនុញ្ញ។

## ៣.២. អភិបាលកិច្ច

ល័ក្ខខ័ណ្ឌតម្រូវផ្នែកច្បាប់ នៅមានកម្រិតនៅឡើយដើម្បីធានាឱ្យសាធារណជន ទទួលបានព័ត៌មានស្តីពីការរៀបចំ ការប្រព្រឹត្តិទៅ និងការធ្វើសេចក្តីសម្រេចរបស់ស្ថាប័នតុលាការនៅក្នុងប្រទេសកម្ពុជា។

នៅក្នុងការអនុវត្តជាក់ស្តែង សាធារណជនអាចចូលរួមសវនាការជាសាធារណៈលើរឿងក្តីរបស់តុលាការ ជាពិសេសរឿងក្តីព្រហ្មទណ្ឌ។ តែគេអាចលំបាកនឹងដឹងបានថាតើនៅពេលដែលសវនាការនឹងត្រូវចាប់ផ្តើម ព្រោះថាតុលាការភាគច្រើនមិនផ្តល់ដំណឹងអំពីកាលបរិច្ឆេទសវនាការរបស់ខ្លួនឡើយ លើកលែងតែតុលាការដែលបច្ចុប្បន្នកំពុងតែធ្វើការជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅក្នុងគម្រោងសង្កេតការណ៍សវនាការ។

ការរឹតត្បិតគួរឱ្យកត់សម្គាល់ ពាក់ព័ន្ធនឹងតម្លាភាព គឺនៅត្រង់ថា ប្រជាពលរដ្ឋមិនអាចទទួលបានព័ត៌មានស្តីពីការតែងតាំង ការផ្លាស់ប្តូរឬការព្យួរការងារចៅក្រមឡើយ។ លើសពីនេះទៀត ក៏គ្មានគេហទំព័ររួមស្តីពីស្ថាប័នតុលាការឡើយ។ ឧទាហរណ៍ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងតុលាការកំពូលជាដើម ពុំមានគេហ-ទំព័រទេ។ មានលេខកូដឈ្មោះសម្រាប់ក្រសួងយុត្តិធម៌ ក៏ប៉ុន្តែការតភ្ជាប់ទៅគេហទំព័រនោះឧស្សាហ៍មិនដំណើរការ។

## ៣.៣. តួនាទី

ស្ថាប័នតុលាការមិនមានប្រសិទ្ធភាពឡើយក្នុងការត្រួតពិនិត្យកំហុសឆ្គងរបស់អង្គនីតិប្រតិបត្តិ។

ការណ៍នេះបង្ហាញថាការត្រួតពិនិត្យ និងតុល្យភាពអំណាចនៅមានកម្រិតយ៉ាងខ្លាំងដើម្បីទប់ទល់មិនឱ្យមានការជ្រៀតជ្រែកពីអង្គនីតិប្រតិបត្តិដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។

រដ្ឋធម្មនុញ្ញចែងថា តុលាការមានអំណាចទៅលើរឿងក្តីរដ្ឋបាលរបស់អង្គនីតិប្រតិបត្តិ។ ទោះយ៉ាងណា ក៏គ្មានក្រមរដ្ឋបាលឬក្រមនីតិវិធីរដ្ឋបាលឡើយ។ ដូច្នេះ ទោះបីជារឿងក្តីរដ្ឋបាលអាចត្រូវបានជំនុំជម្រះដោយតុលាការក៏ដោយ ក៏គ្មានព័ត៌មាន ឬបទដ្ឋាននីតិវិធីណាដែលចែងអំពីរបៀបស៊ើបអង្កេត និងតាមដានរឿងក្តីបែបនេះឡើយ។

ស្ថាប័នតុលាការជាស្ថាប័នមួយដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងររួចស្រេចទៅហើយ ពីអំពើពុករលួយនោះ តាមរយៈការកាត់ទោសនិងសកម្មភាពដទៃទៀត។ ស្ថាប័នតុលាការបានជួយដំណើរការកាត់សេចក្តីរឿងក្តីពុករលួយមួយចំនួនដែលបង្ហាញថាមានការប្តេជ្ញាចិត្តមួយកម្រិតក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ប៉ុន្តែចំនួនរឿងក្តីនៅមានចំនួនតិចតួចនៅឡើយ។

## ៣.៤. អនុសាសន៍

- រដ្ឋាភិបាលត្រូវបង្កើនប្រាក់បៀវត្សរ៍ និងកំណត់ច្បាប់ស្តីពីប្រាក់បៀវត្សរ៍ម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិកតុលាការ ទៅតាមតួនាទី និងតំណែង។
- ធានាថាចៅក្រមត្រូវបានជ្រើសរើសដោយឯករាជ្យ។ ការធ្វើបែបនេះនឹងធានាថា បេក្ខជនដែលមានគុណភាពល្អជាងគេ ត្រូវបានជ្រើសរើស ហើយពួកគេក៏មិនមានអារម្មណ៍ថាបានជំពាក់គុណអ្នកនយោបាយណាម្នាក់ ឬចៅក្រមជាន់ខ្ពស់ណាម្នាក់ ដែលបានចាត់តាំងពួកគេឡើយ។
- បង្កើត និងអនុវត្តន៍កម្មវិធីសិក្សាដើម្បីធានាថានៅតាមសាលាវិទ្យាល័យមានការបង្រៀនអំពីមុខងាររបស់តុលាការ តួនាទីរបស់ព្រះរាជអាជ្ញា តួនាទីរបស់មេធាវី តួនាទីរបស់ចៅក្រម សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងអ្វីដែលជាប់ពាក់ព័ន្ធទាំងអស់ ដូច្នេះ មនុស្សពេញវ័យទាំងអស់នឹងមានការយល់ដឹងអំពីប្រព័ន្ធតុលាការ និងកិច្ចដំណើរការនីតិវិធីរបស់ស្ថាប័នតុលាការ។ ■

# ៤ វិស័យសាធារណៈ

## ៤.១. សមត្ថភាព

កង្វះខាតធនធានសំខាន់ៗ ប្រាក់បៀវត្សរ៍មិនគ្រប់គ្រាន់ និងសមត្ថភាពបច្ចេកទេសមិនគ្រប់គ្រាន់របស់បុគ្គលិក ធ្វើឱ្យការអនុវត្តគម្រោង និងការផ្តល់សេវាកម្មនៅមានកម្រិតនៅឡើយ។ រដ្ឋាភិបាលបានអនុម័តវិធានការមួយចំនួនដើម្បីបំពេញចន្លោះប្រហោងទាំងនេះ ប៉ុន្តែបញ្ហាទាំងនេះគឺពាក់ព័ន្ធនឹងហិរញ្ញវត្ថុធ្ងន់ធ្ងរ។

ប្រជាពលរដ្ឋដែលមានចំណេះដឹង ត្រូវបានសម្លាប់នៅក្រោមរបបខ្មែរក្រហមនៅទសវត្សរ៍ឆ្នាំ១៩៧០ ហើយវិស័យអប់រំមិនត្រូវបានស្តារឡើងវិញឱ្យបានទូលំទូលាយទេ រហូតដល់ទសវត្សរ៍ ឆ្នាំ១៩៩០ ទើបធនធានមនុស្ស ជំនាញសមត្ថភាព និងជំនាញវិជ្ជាជីវៈនៅក្នុងវិស័យសាធារណៈ នៅមានកម្រិតនៅឡើយ។ ថ្វីត្បិតតែប្រព័ន្ធអប់រំមានការរីកចម្រើនយ៉ាងច្រើននៅក្នុងរយៈពេល ២០ឆ្នាំកន្លងមកនេះ ក៏ប៉ុន្តែប្រព័ន្ធនេះនៅតែមិនទាន់អាចបង្កើតអ្នកជំនាញវិជ្ជាជីវៈឱ្យបានគ្រប់គ្រាន់ ដែលអាចបំពេញការងារនៅកម្រិតចាំបាច់ដើម្បីទ្រទ្រង់វិស័យនេះបាននៅឡើយ។

មន្ត្រីរាជការទទួលបានប្រាក់បៀវត្សរ៍ទាប ដែលមិនអាចផ្គត់ផ្គង់តម្រូវការជីវភាពប្រចាំថ្ងៃឱ្យបានគ្រប់គ្រាន់ទេ។ មន្ត្រីរាជការថ្នាក់ទាបទទួលបានប្រាក់បៀវត្សរ៍ ៤០ដុល្លារក្នុងមួយខែ។ ប្រាក់បៀវត្សរ៍គោលជាមធ្យម របស់មន្ត្រីរាជការទូទៅមានចំនួន១០៥ដុល្លារក្នុងមួយខែ។

ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឆ្នាំ១៩៩៤ តម្រូវឱ្យមន្ត្រីរាជការមានអព្យាក្រឹតភាព នៅពេលបំពេញមុខងាររបស់ខ្លួន។ នេះមានន័យថា នៅពេលដែលមន្ត្រីរាជការកំពុងអនុវត្តន៍ការងារក្នុងតួនាទីផ្លូវការរបស់ខ្លួន ពួកគាត់មិនត្រូវបំពេញការងារដើម្បីបម្រើ ឬប្រឆាំងនឹងបេក្ខជននយោបាយ ឬគណបក្សនយោបាយណាមួយឡើយ។ លើសពីនេះទៀត ពួកគាត់ត្រូវបានហាមប្រើប្រាស់ធនធានរដ្ឋសម្រាប់ធ្វើសកម្មភាពនយោបាយ។

## ៤.២. អភិបាលកិច្ច

មានបទប្បញ្ញត្តិមួយចំនួន ប៉ុន្តែបទប្បញ្ញត្តិទាំងនោះមិនបានចែងគ្រប់ផ្នែកទាំងអស់ដែលទាក់ទងនឹងតម្លាភាពនៅក្នុងវិស័យសាធារណៈនោះទេ។ ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននៅមិនទាន់បានអនុម័ត ហើយបទប្បញ្ញត្តិមានស្រាប់មួយចំនួននៅមានចន្លោះប្រហោង។

នៅក្នុងប្រទេសកម្ពុជា ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននៅមិនទាន់អនុម័តដែលនេះបង្ហាញពីភាពនៅមានកម្រិតនៃច្បាប់ការពារទាក់ទងនឹងតម្លាភាពនៅក្នុងវិស័យសាធារណៈ។

ប្រជាពលរដ្ឋមានសិទ្ធិទទួលបានព័ត៌មានក្នុងលំនាំផ្សេងៗគ្នាមានអំពីសកម្មភាពការងារ និងឯកសារផ្សេងៗរបស់វិស័យសាធារណៈ។ ក្នុងករណីមួយចំនួន វិស័យសាធារណៈបង្ហាញឱ្យឃើញពីការអនុវត្តបានយ៉ាងល្អមែនទែន ដោយផ្តល់ព័ត៌មានជាច្រើនដល់សាធារណជន។ គ.ជ.អ.ប.បានអនុវត្តន៍គម្រោងគំនិតផ្តួចផ្តើមយ៉ាងច្រើនគួរឱ្យកោតសរសើរ។

ក្រៅពីករណីមួយចំនួនតូចដែលសាធារណជនបានដឹងទាក់ទងនឹងការប្រព្រឹត្តខុសរបស់មន្ត្រីជាន់ខ្ពស់នោះ ព័ត៌មានអំពីករណីពាក់ព័ន្ធនឹងមន្ត្រីថ្នាក់ទាប គេមិនបានផ្សព្វផ្សាយជាសាធារណៈទេ។

## ៤.៣. តួនាទី

វិស័យសាធារណៈកំពុងអនុវត្តន៍វិធានការយ៉ាងសកម្មមួយចំនួនដើម្បីអប់រំសាធារណជនអំពីអំពើពុករលួយ និងតួនាទីរបស់ប្រជាជនក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

ការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅតែជាអាទិភាពមួយរបស់រដ្ឋាភិបាលនីតិកាលបច្ចុប្បន្ននេះ ឆ្នាំ២០១៣-២០១៨ ដូចបានបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រចតុកោណដើម្បីកំណើនដំណាក់កាលទី៣។ ការពង្រឹងការអប់រំរួមមានការបញ្ជ្រាបការយល់ដឹងអំពីច្បាប់ប្រឆាំងអំពើពុករលួយ និងការលើកកម្ពស់ការយល់ដឹង ជាពិសេសក្នុងចំណោមយុវជន អំពីផលប៉ះពាល់ដែលបណ្ដាលមកពីអំពើពុករលួយ។

ស្ថាប័នសាធារណៈបានអនុវត្តន៍គម្រោងជាច្រើនដើម្បីជួយកាត់បន្ថយអំពើពុករលួយដោយសហការជាមួយនឹងក្រុមហ៊ុនអាជីវកម្ម អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិល។ ទោះបីជាមានភាពជោគជ័យខ្លះក៏ដោយ ក៏ការអនុវត្តល្អនៅមិនទាន់បានទូលំទូលាយនៅគ្រប់ផ្នែកនៃវិស័យសាធារណៈនៅឡើយ។

## ៤.៤. អនុសាសន៍

- ធានាថាការជ្រើសរើសចូលបម្រើការងារនៅក្នុងវិស័យសាធារណៈ គឺមានលក្ខណៈបើកចំហដល់ប្រជាពលរដ្ឋគ្រប់រូបមិនគិតពីទំនាក់ទំនងនយោបាយ ដែលនេះគឺជាជំហានមួយ ដើម្បីការពារភាពមិនលម្អៀងរបស់វិស័យនេះ។
- គ្រប់ស្ថាប័ន និងក្រសួងនៅក្នុងវិស័យសាធារណៈគួរយកគម្រូតាមការអនុវត្តល្អរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងការចេញផ្សាយព័ត៌មានលម្អិតតាមអ៊ីនធើណេត អំពីការចំណាយ កិច្ចសន្យាលទ្ធកម្ម និងអ្នកដេញថ្លៃ ហើយឱ្យសាធារណជនទាំងអស់អាចទទួលបានព័ត៌មានទាំងនោះ។
- សង្គមស៊ីវិល និងសហគមន៍ម្ចាស់ជំនួយ ត្រូវធ្វើការជាមួយរដ្ឋាភិបាល និងវិស័យសាធារណៈ ដើម្បីធានាថា មន្ត្រីសាធារណៈមិនមានភាពលម្អៀងផ្នែកនយោបាយ។ មន្ត្រីរាជការស៊ីវិលមិនត្រូវធ្វើយុទ្ធនាការឃោសនាឱ្យគណបក្សនយោបាយក្នុងតួនាទីផ្លូវការរបស់ខ្លួន ហើយមិនត្រូវប្រើប្រាស់ធនធានរដ្ឋដើម្បីធ្វើយុទ្ធនាការឃោសនានយោបាយនៅពេលណាក៏ដោយ។ សង្គមស៊ីវិល និងម្ចាស់ជំនួយត្រូវចាត់វិធានការតាមដាន និងឱ្យវិស័យសាធារណៈមានគណនេយ្យភាពចំពោះបញ្ហានេះ។ ■

# ៥ ទីភ្នាក់ងារអនុវត្តន៍ច្បាប់

## ៥.១. សមត្ថភាព

មិនមានច្បាប់ដែលកំណត់លក្ខខ័ណ្ឌការងារ និងការបែងចែកថវិកាសម្រាប់ទីភ្នាក់ងារអនុវត្តន៍ច្បាប់នៅក្នុងប្រទេសកម្ពុជាទេ។ ទោះយ៉ាងណាព័ត៌មានអំពីប្រាក់បៀវត្សរ៍របស់នគរបាលជាតិ កងរាជអាវុធហត្ថ និងព្រះរាជអាជ្ញា មានចែងនៅក្នុងអនុក្រឹត្យផ្សេងៗ។

ថវិកាប្រចាំឆ្នាំសម្រាប់នគរបាលជាតិ កងរាជអាវុធហត្ថ និងព្រះរាជអាជ្ញា គឺស្ថិតនៅក្រោមក្រសួងផ្សេងៗ ជាពិសេសក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងយុត្តិធម៌។ ច្បាប់ស្តីពីថវិកាជាតិប្រចាំឆ្នាំ គ្រាន់តែចែងអំពីតួលេខសរុបសម្រាប់ក្រសួងនីមួយៗប៉ុណ្ណោះ ដែលនេះធ្វើឱ្យមានការលំបាកក្នុងការបញ្ជាក់ថាតើមានថវិកាចំនួនប៉ុន្មានត្រូវបែងចែកដល់ប្រតិបត្តិការរបស់ទីភ្នាក់ងារអនុវត្តន៍ច្បាប់នីមួយៗ។ ហាក់ដូចជាពុំមានបទប្បញ្ញត្តិច្បាប់ដែលធានាដល់ប្រតិបត្តិការដើម្បីឱ្យប្រាកដថា នគរបាលជាតិ និងកងរាជអាវុធហត្ថ អាចបំពេញតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពនោះឡើយ។ និយ័តកម្មផ្នែកច្បាប់ដែលមាននៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃអង្គចៅក្រម និងព្រះរាជអាជ្ញា ឬទាក់ទងនឹងប្រាក់បៀវត្សរ៍ លក្ខខ័ណ្ឌការងារ និងការកំណត់ថវិការបស់ស្ថាប័នអយ្យការ កាន់តែមានកម្រិតថែមទៀត។

ប្រាក់បៀវត្សរ៍របស់ចៅក្រមនិងព្រះរាជអាជ្ញា ត្រូវបានតម្លើងនៅឆ្នាំ២០០៣ តាមអនុក្រឹត្យស្តីពីប្រាក់ឧបត្ថម្ភនៃអង្គចៅក្រម។ ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ព្រះរាជអាជ្ញា ខុសគ្នាអាស្រ័យលើអតីតភាពការងារ។

ភ្នាក់ងារអនុវត្តន៍ច្បាប់មានធនធានហិរញ្ញវត្ថុមិនគ្រប់គ្រាន់ឡើយ។ ដូច្នេះ ការអនុវត្តការងារមិនអាចធ្វើឡើងឱ្យមានប្រសិទ្ធភាពគ្រប់ពេលបានទេ។

ឯករាជ្យភាពរបស់ទីភ្នាក់ងារអនុវត្តន៍ច្បាប់នៅកម្ពុជានៅមានកម្រិត។ មានច្បាប់ការពារតិចតួចទប់ទល់នឹងទម្លាប់បក្សពួកនិយមក្នុងការជ្រើសរើសបុគ្គលិក ហើយក៏មានច្បាប់ការពារតិចតួចផងដែរទល់នឹងការជ្រៀតជ្រែកផ្នែកនយោបាយ។

លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសមន្ត្រីកងរាជអាវុធហត្ថ មានចែងនៅក្នុងប្រកាសរបស់ក្រសួងការពារជាតិ។ ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាក់ទងនឹងការតម្លើងឋានន្តរសក្តិយោធិនមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ។ ជាពិសេស យោធិនដែលមានបំណងទទួលបានការតម្លើងឋានន្តរសក្តិ ត្រូវប្រាកដថាឈ្មោះរបស់ខ្លួនមាននៅក្នុងបញ្ជីតម្លើងឋានន្តរសក្តិ ហើយការតម្លើងឋានន្តរសក្តិ គួរធ្វើឡើងដោយអនុវត្តន៍តាមរយៈពេលអប្បបរមានៃអតីតភាពបម្រើការងារតាមកម្រិតនីមួយៗ។

នៅក្នុងការអនុវត្តជាក់ស្តែង ទីភ្នាក់ងារអនុវត្តន៍ច្បាប់នៅក្នុងប្រទេសកម្ពុជា មិនមានឯករាជ្យភាពទេ។ នយោបាយភាវូបនីយកម្មទៅលើទីភ្នាក់ងារអនុវត្តន៍ច្បាប់ ជាពិសេសការជ្រើសរើសបុគ្គលិក គឺនាំឱ្យខូចខាតដល់ការបែងចែកស្ថាប័ននេះឱ្យដាច់ចេញពីអំណាចប្រតិបត្តិរបស់រដ្ឋាភិបាល។

## ៥.២. អភិបាលកិច្ច

មានបទប្បញ្ញត្តិតិចតួចដែលធានាថា សាធារណជនអាចទទួលបានព័ត៌មានពាក់ព័ន្ធនឹងទីភ្នាក់ងារអនុវត្តន៍ច្បាប់នៅក្នុងប្រទេសកម្ពុជា។ ករណីពុំមានច្បាប់ចាំបាច់នៅក្នុងករណីខ្លះ ឬពុំមានការបញ្ជាក់ឱ្យបានច្បាស់លាស់គ្រប់គ្រាន់ នៅក្នុងយន្តការដែលមានស្រាប់ គឺជាហេតុនាំឱ្យមានច្បាប់ការពារតែត្រឹមកម្រិតណាមួយប៉ុណ្ណោះ ដើម្បីធានាតម្លាភាពទីភ្នាក់ងារអនុវត្តន៍ច្បាប់។

ព័ត៌មានខ្លះទាក់ទងនឹងទីភ្នាក់ងារអនុវត្តន៍ច្បាប់អាចទទួលបានតាមអ៊ីនធើណេត ប៉ុន្តែព័ត៌មានជាច្រើនទៀត ដូចជាការប្រកាសទ្រព្យសម្បត្តិ និងរបាយការណ៍សកម្មភាពមិនត្រូវបានផ្សព្វផ្សាយទេ។

មានច្បាប់មួយចំនួនដែលធានាថា ទីភ្នាក់ងារអនុវត្តន៍ច្បាប់មានគណនេយ្យភាពចំពោះសកម្មភាពរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ មានការកម្រិតមួយចំនួននៅក្នុងច្បាប់ទាក់ទងនឹងការរាយការណ៍សកម្មភាពរបស់នគរបាល និងនីតិវិធីដាក់វិន័យចំពោះព្រះរាជអាជ្ញា។

គណនេយ្យភាពរបស់ទីភ្នាក់ងារអនុវត្តន៍ច្បាប់ហាក់ដូចជានៅមានកម្រិតនៅឡើយនៅក្នុងការអនុវត្តជាក់ស្តែង។ ការប៉ះទង្គិចរវាងបាតុករជាជនស៊ីវិលជាមួយនគរបាលជាតិ និងកងរាជអាវុធហត្ថ បានបង្កឱ្យមានកង្វល់ពីក្រុមសិទ្ធិមនុស្សអំពីគណនេយ្យភាពរបស់ទីភ្នាក់ងារអនុវត្តន៍ច្បាប់ទាំងពីរនេះ។

មានបទប្បញ្ញត្តិមួយចំនួនតូចដើម្បីការពារសុចរិតភាពរបស់នគរបាល និងព្រះរាជអាជ្ញា ប៉ុន្តែបទប្បញ្ញត្តិទាំងនោះមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយហើយមានចន្លោះប្រហោងច្រើន។

សកម្មភាពដែលបានអនុវត្តន៍ នៅមានកម្រិតនៅឡើយដើម្បីធានាឱ្យមានសុចរិតភាពក្នុងចំណោមទីភ្នាក់ងារអនុវត្តន៍ច្បាប់។ ប៉ុន្តែការរំលោភបំពានលើគោលការណ៍ណែនាំក្រមសីលធម៌ហាក់ដូចជាកើតឡើងជាទូទៅ។

## ៥.៣. តួនាទី

ទីភ្នាក់ងារអនុវត្តន៍ច្បាប់ ដើរតួនាទីមួយកម្រិតក្នុងការតាមដាន និងស៊ើបអង្កេតករណីពុករលួយនៅក្នុងប្រទេសកម្ពុជា។ បញ្ហានេះ មួយផ្នែកគឺដោយសារការដាក់ពង្រាយមន្ត្រីអង្គភាពប្រឆាំងអំពើពុករលួយដែលទទួលបានសិទ្ធិអំណាចចម្បងដើម្បីបំពេញការងារនេះ។

មិនមានអង្គភាពនគរបាលពិសេសដែលចាត់តាំងឡើងដើម្បីស៊ើបទាក់ទងនឹងអំពើពុករលួយទេ។ ភារកិច្ចការងារនេះ ធ្លាក់លើអង្គភាពប្រឆាំងអំពើពុករលួយទៅវិញ។

នៅក្នុងការអនុវត្តជាក់ស្តែង អ្វីដែលកើតឡើងគឺថា អង្គភាពប្រឆាំងអំពើពុករលួយ ធ្វើការស៊ើបអង្កេតបឋមលើករណីអំពើពុករលួយ បន្ទាប់មកបញ្ជូនទៅព្រះរាជអាជ្ញាជាប់ពាក់ព័ន្ធ។

## ៥.៤. អនុសាសន៍

- រៀបចំសេចក្តីព្រាង និងអនុម័តច្បាប់ស្តីពីនគរបាលដោយធ្វើការបែងចែកឱ្យដាច់ស្រឡះរវាងកងរាជអាវុធហត្ថ នគរបាលស៊ីវិល និងនគរបាលយុត្តិធម៌។
- ជ្រើសរើសមន្ត្រីនគរបាលជាស្ត្រីឱ្យបានច្រើនថែមទៀត។ ផ្សព្វផ្សាយអំពីស្ត្រីគម្រូដ៏ល្អនៅក្នុងជួរនគរបាល នៅតាមសាកលវិទ្យាល័យដើម្បីលើកទឹកចិត្តស្ត្រីឱ្យចូលធ្វើជានគរបាលជាជម្រើសអាជីពមួយ។
- ម្ចាស់ជំនួយ គួរផ្តល់មូលនិធិថែមទៀតដល់បណ្ឌិតសភានគរបាលកម្ពុជា ដើម្បីលើកកម្ពស់ការបណ្តុះបណ្តាល និងសមត្ថភាពរបស់នគរបាលជាតិ។ ■

# ៦ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ៦.១. សមត្ថភាព

មានកង្វះខាតធនធានយ៉ាងច្រើន នៅក្នុងថវិការបស់គ.ជ.ប.ជាពិសេសទាក់ទងនឹងការអភិវឌ្ឍសមត្ថភាព និងការបណ្តុះបណ្តាលបុគ្គលិក។ នៅក្នុងការអនុវត្តជាក់ស្តែងនេះមានន័យថា គ.ជ.ប.ពុំមានលទ្ធភាពបំពេញភារកិច្ចទាំងអស់របស់ខ្លួនប្រកបដោយប្រសិទ្ធភាពនោះទេ។

មានច្បាប់ និងបទប្បញ្ញត្តិមួយចំនួនដែលការពារឯករាជ្យភាពរបស់គ.ជ.ប.ទោះបីជាច្បាប់ និងបទប្បញ្ញត្តិទាំងនេះមិនបានការពារគ្រប់ផ្នែកទាំងអស់នៃឯករាជ្យភាពនេះក្តី។

គ.ជ.ប.ស្ថិតនៅក្រោមក្រសួងមហាផ្ទៃ ដូច្នេះ គ.ជ.ប. គ្មានលក្ខន្តិកៈផ្ទាល់ខ្លួនតាមរដ្ឋធម្មនុញ្ញទេ។ ប៉ុន្តែរដ្ឋធម្មនុញ្ញពិតជាលើកអំពីស្ថាប័នមួយដែលទទួលខុសត្រូវក្នុងការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

យោងតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចែងលម្អិតអំពីមុខងារដែលគ.ជ.ប.ត្រូវអនុវត្តន៍។ទាក់ទងនឹងឯករាជ្យភាពរបស់គ.ជ.ប.ច្បាប់នេះចែងថា ភារកិច្ចក្នុងការរៀបចំការបោះឆ្នោត ត្រូវអនុវត្តន៍ប្រកបដោយអព្យាក្រឹតមិនលម្អៀង។ ច្បាប់នេះត្រូវអនុវត្តន៍ចំពោះសមាជិកគ.ជ.ប. និងបុគ្គលិកគណៈកម្មាធិការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

គ.ជ.ប.មិនបានបំពេញមុខងាររបស់ខ្លួនប្រកបដោយឯករាជ្យភាពទេ។ មានឥទ្ធិពលច្រើនពីគណបក្សកាន់អំណាចគ្រប់គ្រងប្រទេសដែលធ្វើឱ្យប៉ះពាល់ដល់ការធ្វើសេចក្តីសម្រេចនិងចំណាត់ការរបស់ស្ថាប័ននេះ។

ការតែងតាំងបុគ្គលិកថ្នាក់ជាតិ និងថ្នាក់ខេត្តត្រូវបានគេរាយការណ៍ថាមានជាប់ពាក់ព័ន្ធនឹងរឿងនយោបាយ។ ការតែងតាំងទាំងនេះពុំមាននិន្នាការផ្អែកលើស្នាដៃ និងគុណវុឌ្ឍិទេ តែផ្អែកលើទំនាក់ទំនងផ្នែកនយោបាយវិញ។ ឯករាជ្យភាពក្នុងដំណើរការជ្រើសរើសបុគ្គលិកមុនការបោះឆ្នោតជាតិឆ្នាំ២០១៣ មានភាពមន្ទិលសង្ស័យ។ គេបានរាយការណ៍ថា មិនមានការអនុវត្តតាមនីតិវិធីត្រួតពិនិត្យគុណភាពផ្លូវការដើម្បីតែងតាំងគណៈកម្មការខេត្ត រាជធានីរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោតទេ។

ចំណុចមួយដែលមានការរិះគន់យ៉ាងខ្លាំងគឺការដកឈ្មោះអ្នកដែលមានសិទ្ធិបោះឆ្នោតចេញពីបញ្ជីឈ្មោះបោះឆ្នោតក៏ដូចជាបញ្ហាមានឈ្មោះអត់សុពលភាព និងឈ្មោះជាន់គ្នានៅក្នុងបញ្ជីឈ្មោះបោះឆ្នោត។

## ៦.២. អភិបាលកិច្ច

មានបទប្បញ្ញត្តិមួយចំនួនដែលធានាថាសាធារណជន អាចទទួលបានព័ត៌មានស្តីពីសកម្មភាពពាក់ព័ន្ធរបស់គ.ជ.ប.។ ប៉ុន្តែព័ត៌មានស្តីពីហិរញ្ញវត្ថុរបស់គណបក្សនយោបាយ មិនតម្រូវឱ្យមានការផ្សព្វផ្សាយជាសាធារណៈទេ។

សាធារណជនអាចទទួលបានព័ត៌មានពាក់ព័ន្ធមួយចំនួនស្តីពីការរៀបចំ និងការបំពេញមុខងាររបស់គ.ជ.ប.នៅក្នុងការអនុវត្តជាក់ស្តែង ប៉ុន្តែព័ត៌មានលម្អិតស្តីពីសកម្មភាព និងការចំណាយរបស់គ.ជ.ប.មិនមានជាសាធារណៈទេ។

ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋានគ.ជ.ប. ធ្វើសេចក្តីប្រកាសជូនដំណឹងសាធារណៈផ្សព្វផ្សាយនៅលើទំព័រសារព័ត៌មាននិងផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងប្រតិទិននៃការបោះឆ្នោត ព្រមទាំងការចុះឈ្មោះបោះឆ្នោត។ ប៉ុន្តែមានតម្លាភាពតិចតួចនៅថ្នាក់មូលដ្ឋាន ទាក់ទងនឹងបញ្ហាដូចជាដំណោះស្រាយពាក្យបណ្តឹង នីតិវិធីជ្រើសរើសបុគ្គលិក និងលទ្ធភាពទទួលបានព័ត៌មានជាដើម។

មានបទប្បញ្ញត្តិមួយចំនួនដែលធានាថាគ.ជ.ប. មានគណនេយ្យភាព។ ប៉ុន្តែបទប្បញ្ញត្តិទាំងនេះមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីធានាថាស្ថាប័ននេះមានគណនេយ្យភាពគ្រប់គ្រាន់ទេ។

យោងតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រធាន អនុប្រធាន និងសមាជិកទាំងអស់របស់គ.ជ.ប.ដែលត្រូវបានតែងតាំងថ្មីតម្រូវឱ្យធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង។ ប៉ុន្តែច្បាប់នេះពុំមានសរសេរបញ្ចូលខ្លឹមសារនៃពាក្យសម្បថនោះទេ។ លើសពីនេះទៀត បុគ្គលិកគណៈកម្មការការិយាល័យបោះឆ្នោតត្រូវស្បថថាខ្លួននៅអព្យាក្រឹត និងមិនលម្អៀងចាប់ពីពេលចូលបម្រើការងារ។

គ.ជ.ប. ចាត់វិធានការមួយចំនួនដើម្បីធានាថា សមាជិករបស់ខ្លួនមានសុចរិតភាព។ ប៉ុន្តែ គ.ជ.ប.ទំនងជាពុំមានប្រសិទ្ធភាពទាំងស្រុងក្នុងការដាក់ទោសចំពោះការប្រព្រឹត្តខុសប្រក្រតីទេ។

## ៦.៣. តួនាទី

គ. ជ. ប. ចាត់វិធានការនៅមានកម្រិតនៅឡើយក្នុងការកំណត់ហិរញ្ញវត្ថុសម្រាប់បេក្ខជន និងគណបក្សនយោបាយ។ នៅក្នុងអំឡុងពេលបោះឆ្នោតគ.ជ.ប.ត្រូវតែធ្វើសវនកម្មលើចំណូល និងចំណាយផ្នែកហិរញ្ញវត្ថុ របស់បេក្ខជន ឬគណបក្សនយោបាយ។

តាមច្បាប់ គ.ជ.ប.ត្រូវធានាថា គ្រប់គណបក្សនយោបាយទាំងអស់ត្រូវទទួលបានលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយស្មើភាពគ្នា។ ប៉ុន្តែទង្វើបែបនេះពុំមានទេនៅក្នុងការអនុវត្តជាក់ស្តែង ហើយប្រព័ន្ធផ្សព្វផ្សាយភាគច្រើនលម្អៀងទៅគណបក្សកាន់អំណាច។ ការជ្រើសរើសបុគ្គលិក និងការជ្រើសរើសសមាជិកទាំងនេះ ពុំមានបើកចំហទេ។

តាមច្បាប់ គ.ជ.ប.ត្រូវធានាថា គ្រប់គណបក្សនយោបាយទាំងអស់ត្រូវទទួលបានលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយស្មើភាពគ្នា។

គ.ជ.ប.សកម្មខ្លះដែរក្នុងការស្វះស្វែងធានាឱ្យមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ ប៉ុន្តែភាពជោគជ័យរបស់ខ្លួននៅមានកម្រិត អាស្រ័យដោយសារ សមត្ថភាពរបស់ខ្លួននៅមានកម្រិត និងខ្វះឯករាជ្យភាព។

## ៦.៤. អនុសាសន៍

- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគួរអនុវត្តន៍ដាច់ខាតនូវគោលការណ៍តម្លាភាព និងមិនលម្អៀងនៅក្នុងការជ្រើសរើសមន្ត្រីរៀបចំការបោះឆ្នោតនៅគ្រប់កម្រិតទាំងអស់។
- ម្ចាស់ជំនួយអន្តរជាតិ គួរដាក់បន្ថែមកំណែទម្រង់បោះឆ្នោតជាបទដ្ឋានវាស់វែង ជាគន្លឹះមួយសម្រាប់ឱ្យរដ្ឋាភិបាលទទួលបានមូលនិធិឧបត្ថម្ភ។ ■

# ៧ ការិយាល័យប្រជាពលរដ្ឋ

## ៧.១. សមត្ថភាព

ធនធានមនុស្សរបស់ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក និងក្រុមការងារគណនេយ្យភាពថ្នាក់ខេត្តបានពង្រឹងតាមរយៈការរៀបចំគោលការណ៍ណែនាំ និងវគ្គបណ្តុះបណ្តាល។ យ៉ាងណាក៏ដោយធនធានហិរញ្ញវត្ថុរបស់ស្ថាប័នទាំងពីរនេះនៅតែមិនមានស្ថិរភាពដោយសារម្ចាស់ជំនួយលែងផ្តល់មូលនិធិដល់យន្តការគណនេយ្យភាព ហើយមិនមានមូលនិធិគ្រប់គ្រាន់ដែលទទួលបានពីរដ្ឋាភិបាល ជាពិសេសសម្រាប់ក្រុមការងារគណនេយ្យភាពថ្នាក់ខេត្ត។

បទប្បញ្ញត្តិដែលមានស្រាប់ ផ្តល់កិច្ចការពារយ៉ាងរឹងមាំដើម្បីធានាឱ្យមានឯករាជ្យភាព និងវិជ្ជាជីវៈនៅការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក និងក្រុមការងារគណនេយ្យភាពថ្នាក់ខេត្ត។ លើសពីនេះ នៅក្នុងការអនុវត្តជាក់ស្តែង អ្នកដាក់ពាក្យបណ្តឹងនៅការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុកបានរាយការណ៍ថា ពួកគេមានជំនឿជឿជាក់ខ្ពស់លើឯករាជ្យភាពរបស់យន្តការនេះ។

បេក្ខជនប្រកបដោយសក្តានុពលសម្រាប់មុខតំណែងជាការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុកតម្រូវមានលក្ខណៈវិនិច្ឆ័យផ្នែកវិជ្ជាជីវៈបន្ថែមទៀត។ មុនពេលត្រូវបានពិចារណាសម្រាប់មុខតំណែងនេះ ពោលគឺបេក្ខជនត្រូវមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងក្រុង ស្រុក ឬខណ្ឌដែលខ្លួនដាក់ពាក្យ មានបទពិសោធន៍រហូតដល់ ៥ឆ្នាំផ្នែករដ្ឋបាល សង្គមស៊ីវិលឬវិស័យឯកជន និងមានកម្រិតវប្បធម៌ចាប់ពីមធ្យមសិក្សាឡើងទៅ ឬកម្រិតអប់រំដែលមានតម្លៃស្មើ។

## ៧.២. អភិបាលកិច្ច

របាយការណ៍ស្តីពីសកម្មភាពរបស់ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក និងក្រុមការងារគណនេយ្យភាពថ្នាក់ខេត្តបានចេញផ្សាយជាសាធារណៈ។ យ៉ាងណាក៏ដោយរបាយការណ៍ដែលបានចេញផ្សាយ មានមិនបានធ្វើបច្ចុប្បន្នភាពទេ។

ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក និងក្រុមការងារគណនេយ្យភាពថ្នាក់ខេត្ត រាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធដើម្បីធានាឱ្យមានការត្រួតពិនិត្យ និងតុល្យភាពអំណាចមួយចំនួន ប៉ុន្តែពួកគាត់មិនចាំបាច់ផ្សាយជាសាធារណៈនូវព័ត៌មានស្តីពីសកម្មភាពបើកចំហទាំងអស់របស់ពួកគាត់នៅក្នុងការអនុវត្តជាក់ស្តែងទេ។ ការធ្វើដូច្នេះនឹងធ្វើឱ្យសាធារណជនអាចមានលទ្ធភាពនាពេលអនាគត ធ្វើការត្រួតពិនិត្យកំហុសឆ្គងរបស់យន្តការបណ្តឹងនេះ។

នៅក្នុងការអនុវត្តជាក់ស្តែង របាយការណ៍ដែលអាចចូលពិនិត្យមើលបានជាសាធារណៈតាមបណ្តាញអ៊ីនធើណេតគឺរបាយការណ៍ប្រចាំឆ្នាំ និងប្រចាំត្រីមាសស្តីពីការវិវត្តរបស់ការិយាល័យប្រកចេញចូលតែមួយ ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក។

ក្រុមការងារគណនេយ្យភាពថ្នាក់ខេត្តមិនមានកម្រងក្រមសីលធម៌ឡើយ។ ប៉ុន្តែពួកគេត្រូវបានគេរំពឹងថាប្រតិបត្តិតាមសៀវភៅណែនាំផ្ទៃក្នុងរបស់ខ្លួនស្តីពីការដោះស្រាយបណ្តឹង។ ជាពិសេស ក្រុមការងារគណនេយ្យភាពថ្នាក់ខេត្តមានភារកិច្ចរក្សាការសម្ងាត់នៅពេលដែលស៊ើបអង្កេតលើបណ្តឹង។

## ៧.៣. តួនាទី

ទិន្នន័យបង្ហាញថា ការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុកមានប្រសិទ្ធភាពក្នុងការដោះស្រាយបណ្ដឹងដែលខ្លួនទទួលបាន។ យ៉ាងណាក៏ដោយលទ្ធផលនៃការអង្កេតបង្ហាញថាក្រុមការងារគណនេយ្យភាពថ្នាក់ខេត្តប្រើប្រាស់មិនបានល្អឡើយដោយសារតែកង្វះការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីតួនាទី និងមុខងាររបស់ក្រុមការងារនេះ។

តួនាទីរបស់ក្រុមការងារគណនេយ្យភាពថ្នាក់ខេត្ត គឺមិនមែនត្រឹមតែស៊ើបអង្កេតពាក្យបណ្ដឹងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើការស្រាវជ្រាវ និងតស៊ូមតិឱ្យប្រជាពលរដ្ឋអំពីតួនាទី កាតព្វកិច្ច និងនីតិវិធីរបស់ក្រុមការងារគណនេយ្យភាពថ្នាក់ខេត្តទៀតផង។

## ៧.៤. អនុសាសន៍

- ជំរុញឱ្យក្រសួងទាំងអស់បង្វែរមុខងាររដ្ឋបាលរបស់ខ្លួននៅថ្នាក់ក្រោមជាតិ ឱ្យអនុវត្តន៍តាមគម្រូការិយាល័យច្រកចេញចូលតែមួយ ឬការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក។
- បង្កើតការិយាល័យប្រជាពលរដ្ឋថ្នាក់ជាតិ។ ធ្វើការជាមួយការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក និងក្រុមការងារគណនេយ្យភាពថ្នាក់ខេត្តគម្រូ ដើម្បីពង្រីកសេវា និងការអនុវត្តប្រកបដោយប្រសិទ្ធភាពទាំងនេះទៅដល់ថ្នាក់ជាតិ។ ■

# ៨ អាជ្ញាធរសវនកម្មជាតិ

## ៨.១. សមត្ថភាព

មានបទប្បញ្ញត្តិជាច្រើនដែលផ្តល់ឱ្យអាជ្ញាធរសវនកម្មជាតិនូវធនធានដែលខ្លួនត្រូវការ ដើម្បីបំពេញមុខងារប្រកបដោយប្រសិទ្ធភាព។

ច្បាប់សវនកម្ម ឆ្នាំ២០០០ ចែងថាអាជ្ញាធរសវនកម្មជាតិត្រូវមានថវិកាផ្ទាល់ខ្លួនដាច់ដោយឡែកនៅក្នុងកញ្ចប់ថវិកា។ ចំណុចនេះមានសារៈសំខាន់ណាស់ដើម្បីធានាថា អាជ្ញាធរសវនកម្មជាតិគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុរបស់ខ្លួនដោយពុំមានការជ្រៀតជ្រែកមិនសមរម្យពីភាគីខាងក្រៅ។

អាជ្ញាធរសវនកម្មជាតិមានធនធានមួយចំនួន។ ប៉ុន្តែ យ៉ាងណាក្តីកង្វះខាតធនធានគួរឱ្យកត់សម្គាល់បណ្តាលឱ្យមានអប្រសិទ្ធភាពមួយចំនួននៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន។

មានបទប្បញ្ញត្តិមួយចំនួន ប៉ុន្តែបទប្បញ្ញត្តិទាំងនោះមិនចែងគ្រប់ផ្នែកទាំងអស់នៃឯករាជ្យភាពរបស់អាជ្ញាធរសវនកម្មជាតិឡើយ។

ដំណើរការប្រព្រឹត្តទៅប្រចាំថ្ងៃរបស់អាជ្ញាធរសវនកម្មជាតិអាចមានឯករាជ្យ ប៉ុន្តែការចូលរួមរបស់អគ្គសវនករនៅក្នុងសកម្មភាពនយោបាយគឺជាការកម្រិតនូវឯករាជ្យភាព និងភាពអព្យាក្រឹតផ្នែកនយោបាយរបស់អគ្គសវនករ។

## ៨.២. អភិបាលកិច្ច

មានបទប្បញ្ញត្តិត្រឹមកម្រិតណាមួយប៉ុណ្ណោះដែលធានាថាព័ត៌មានពាក់ព័ន្ធស្តីពីសកម្មភាពនិងការធ្វើសេចក្តីសម្រេចរបស់អាជ្ញាធរសវនកម្មជាតិអាចចូលពិនិត្យមើលបានជាសាធារណៈ។

ច្បាប់ស្តីពីសវនកម្មចែងថា មុខងារចម្បងរបស់អាជ្ញាធរសវនកម្មជាតិ គឺត្រូវធ្វើសវនកម្មខាងក្រៅ។ ច្បាប់នេះក៏រៀបរាប់ផងដែរអំពីស្ថាប័នផ្សេងៗដែលជាកម្មវត្ថុនៃការធ្វើសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ។

សាធារណជន និងសមាជិកសភាអាចទទួលបានព័ត៌មានពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរសវនកម្មជាតិ ប៉ុន្តែមានការពន្យារពេល និងមិនសូវមានការបោះពុម្ពផ្សាយរបាយការណ៍សវនកម្មទេ។

លទ្ធភាពមានកម្រិត ក្នុងការទទួលបានព័ត៌មាន នៅបន្តជាបញ្ហាប្រឈមមួយក្នុងការធានាថាអាជ្ញាធរសវនកម្មជាតិមានគណនេយ្យភាពក្នុងការអនុវត្តជាក់ស្តែង។

ក្រមសីលធម៌របស់អាជ្ញាធរសវនកម្មជាតិមានគោលបំណងការពារយន្តការសុចរិតភាពរបស់ស្ថាប័ននេះ។ ក្រមសីលធម៌របស់អាជ្ញាធរសវនករសាធារណៈបានបោះពុម្ពផ្សាយនៅឆ្នាំ២០០២។ ក្រមសីលធម៌នេះមាន៥ជំពូក និងបញ្ញត្តិចំនួន៣១ ដែលផ្តោតលើប្រធានបទជាអាទិ៍ដូចជា៖ ការជឿទុកចិត្ត ទំនុកចិត្តនិងភាពគួរជាទីជឿជាក់បាន សុចរិតភាព ឯករាជ្យភាព សត្យានុម័ត និងភាពមិនលម្អៀង ភាពអព្យាក្រឹតផ្នែកនយោបាយ ទំនាស់ផលប្រយោជន៍ ការរក្សាការសម្ងាត់វិជ្ជាជីវៈ សមត្ថភាព និងការអភិវឌ្ឍវិជ្ជាជីវៈ។

## ៨.៣. តួនាទី

ច្បាប់ស្តីពីសវនកម្មអនុញ្ញាតឱ្យអាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មច្រើនប្រភេទ រួមមានសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រសួងប្រព័ន្ធ

និងប្រតិបត្តិការរបស់ស្ថាប័ន និងសវនកម្មទៅលើការបំពេញការងារ។

អាជ្ញាធរសវនកម្មជាតិផ្តល់ការបណ្តុះបណ្តាលជូនដល់នាយកដ្ឋានផ្ទៃក្នុងនៅបណ្តាក្រសួងនានា។ ការបណ្តុះបណ្តាលបែបនេះមានគោលបំណងបង្កលក្ខណៈឱ្យក្រសួងផ្សេងៗ អាចធ្វើសវនកម្មកាន់តែមានប្រសិទ្ធភាពទៅលើការចំណាយសាធារណៈផ្ទាល់ខ្លួន។

អាជ្ញាធរសវនកម្មជាតិ មានអំណាចក្នុងនៅមានកម្រិតមួយប៉ុណ្ណោះក្នុងការចាប់កំហុស និងដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តខុសរបស់មន្ត្រីសាធារណៈ។

ជារួម កង្វះព័ត៌មានសាធារណៈធ្វើឱ្យមានការលំបាកក្នុងការវាយតម្លៃឱ្យបានពេញលេញទៅលើលទ្ធភាពរបស់អាជ្ញាធរសវនកម្មជាតិក្នុងការរួមចំណែកកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ៨.៤. អនុសាសន៍

- ធ្វើវិសោធនកម្មមាត្រា៤០នៃច្បាប់ស្តីពីសវនកម្មឆ្នាំ២០០០ដើម្បីតម្រូវឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបង្កើតក្រុមសវនកម្មបច្ចេកទេសឯករាជ្យមួយ ដើម្បីធ្វើការត្រួតពិនិត្យសកម្មភាព និងប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិជារៀងរាល់ឆ្នាំ ពោលគឺមិនមែនតែក្នុងករណីបន្ទាន់ទេ។
- អនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដែលតម្រូវឱ្យបើកចំហរបាយការណ៍សវនកម្ម និងរបាយការណ៍ហិរញ្ញវត្ថុរបស់អាជ្ញាធរសវនកម្មជាតិ ជូនដល់សាធារណជននៅក្នុងឆ្នាំសារពើពន្ធពាក់ព័ន្ធ។ ធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីសវនកម្មឆ្នាំ២០០០ ដើម្បីដាក់បញ្ចូលល័ក្ខខ័ណ្ឌតម្រូវមួយនេះ។
- បង្កើតយន្តការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីធានាថាក្រមសីលធម៌ ឆ្នាំ២០០០ របស់អាជ្ញាធរសវនកម្មជាតិ ត្រូវបានបុគ្គលិកទាំងអស់របស់អាជ្ញាធរសវនកម្មជាតិអនុវត្តន៍ និងប្រកាន់ខ្ជាប់។
- ម្ចាស់ជំនួយអន្តរជាតិគួរសង្កត់ធ្ងន់ថា ការធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាព ការរៀបចំរបាយការណ៍សវនកម្ម និងការបោះពុម្ពផ្សាយដោយទៀងទាត់ គឺជាបទដ្ឋានគោលមួយដើម្បីរដ្ឋាភិបាលទទួលបានថវិកាជំនួយ។ ■

# ៩ ស្ថាប័នប្រឆាំងអំពើពុករលួយ

## ៩.១. សមត្ថភាព

មានបទប្បញ្ញត្តិមួយចំនួនដែលធានាថាស.ប.ព. មានធនធានគ្រប់គ្រាន់។ នៅពេលដែលស.ប.ព. ត្រូវបានបង្កើតឡើងដំបូង ច្បាប់ប្រឆាំងអំពើពុករលួយបានប្រគល់ការងារត្រួតពិនិត្យថវិកាទៅឱ្យស្ថាប័នថ្នាក់នីតិប្រតិបត្តិរបស់រដ្ឋាភិបាលគឺគណៈរដ្ឋមន្ត្រី។ បន្ទាប់មក ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយត្រូវបានធ្វើវិសោធនកម្មដើម្បីធានាថា ស.ប.ព.មានថវិកាដាច់ដោយឡែកសម្រាប់ធ្វើសកម្មភាពរបស់ខ្លួន។ បច្ចុប្បន្នថវិការបស់ស.ប.ព.គឺជាផ្នែកមួយនៃថវិកាជាតិ ដូច្នេះត្រូវឆ្លងកាត់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នៅក្នុងនីតិវិធីនេះ ប្រធានអ.ប.ព.ធ្វើសំណើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់មកក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ រៀបចំការចំណាយថវិកានេះ ហើយស្នើសុំការអនុម័តពីនាយករដ្ឋមន្ត្រី។

ស.ប.ព.មានធនធានមួយចំនួនប៉ុន្តែការមានធនធានមិនគ្រប់គ្រាន់នាំឱ្យស្ថាប័ននេះគ្មានប្រសិទ្ធភាពមួយកម្រិតក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

គ្មានការបញ្ជាក់ជាសាធារណៈទេអំពីការត្រួតពិនិត្យក្រមសីលធម៌របស់បេក្ខជនដែលដាក់ពាក្យចូលបម្រើការងារ។ ប៉ុន្តែនៅពេលបានចូលបម្រើការងារ វគ្គបណ្តុះបណ្តាលដំបូងមួយត្រូវបានផ្តល់ជូនគ្រប់បុគ្គលិកថ្មីទាំងអស់។

មានបទប្បញ្ញត្តិតិចតួច ដែលព្យាយាមធានាថាស.ប.ព.មានឯករាជ្យភាព។ ស.ប.ព.គឺជាអង្គភាពផ្លូវការមួយដែលបានបង្កើតឡើងក្រោមច្បាប់ប្រឆាំងអំពើពុករលួយ។ ដំបូងស្ថាប័ននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមគណៈរដ្ឋមន្ត្រី ប៉ុន្តែនៅឆ្នាំ២០១១ ច្បាប់នេះត្រូវបានធ្វើវិសោធនកម្មដើម្បីធានាឱ្យស.ប.ព.មានថវិកាដាច់ដោយឡែក។

ដើម្បីធានាឱ្យមានភាពសត្យានុម័តលក្ខណៈវិនិច្ឆ័យវិជ្ជាជីវៈមួយចំនួនត្រូវបានចែងនៅក្នុងច្បាប់ប្រឆាំងអំពើពុករលួយ ទាក់ទងនឹងការជ្រើសរើសសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងសមាជិក អ.ប.ព.។

សមាជិក៧រូបក្នុងចំណោមសមាជិក១១រូបរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ត្រូវបានជ្រើសរើសដោយស្ថាប័នសាធារណៈផ្សេងៗដូចជាអាជ្ញាធរសវនកម្មជាតិ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងរាជរដ្ឋាភិបាល។

ប្រតិបត្តិការរបស់ស.ប.ព.មិនអាចចាត់ទុកថាមិនប្រកាន់បក្សពួកបានទេ ពីព្រោះថាស្ថាប័ននេះមានការពាក់ព័ន្ធនយោបាយ។ តាមរយៈការតែងតាំងមន្ត្រីអ.ប.ព. តាមខ្សែរយៈនយោបាយជាពិសេស គឺប្រធានអ.ប.ព.។

## ៩.២. អភិបាលកិច្ច

មានបទប្បញ្ញត្តិច្បាប់ខ្លះដែលតម្រូវឱ្យសាធារណជនមានសិទ្ធិទទួលព័ត៌មានអំពីសកម្មភាពនិងដំណើរការសេចក្តីសម្រេចរបស់ស.ប.ព.។ គ្រប់សកម្មភាពទាំងអស់របស់អ.ប.ព.រួមទាំងការស៊ើបអង្កេត និងការធ្វើសេចក្តីសម្រេចលើករណីប្រឆាំងអំពើពុករលួយផង ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ។ បន្ទាប់មកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយរាយការណ៍ជូននាយករដ្ឋមន្ត្រី រៀងរាល់ឆមាស ឬប្រចាំឆ្នាំ។

ទោះបីជាសាធារណជនទទួលព័ត៌មានជាប់ពាក់ព័ន្ធមួយចំនួន អំពីការរៀបចំ និងការប្រព្រឹត្ត

ទៅនៃស.ប.ព.ក៏ពិតមែន ក៏ប៉ុន្តែមិនមានព័ត៌មានអំពីសេចក្ដីសម្រេច និងរបៀបធ្វើសេចក្ដីសម្រេចទាំងឡាយនោះទេ។

មានបទប្បញ្ញត្តិច្បាប់តិចតួចដែលធានាថា ស.ប.ព.ធ្វើរបាយការណ៍អំពីសកម្មភាព និងមានគណនេយ្យភាពចំពោះសកម្មភាពរបស់ខ្លួន។

ទោះបីជាមានច្បាប់ និងបទប្បញ្ញត្តិមួយចំនួនក៏ដោយក៏ច្បាប់ និងបទប្បញ្ញត្តិទាំងនេះមិនចែងគ្រប់ជ្រុងជ្រោយទាក់ទងនឹងសុចរិតភាពរបស់សមាជិកស.ប.ព.ដែរ។

ដោយសារថាស.ប.ព.មានលក្ខណៈមិនបើកចំហ ដូច្នេះព័ត៌មានអំពីយន្តការសុចរិតភាពរបស់ខ្លួននៅមានកម្រិតនៅឡើយ។ យោងតាមព័ត៌មានដែលស្វែងរកបានតាមរយៈយន្តការសុចរិតភាពបច្ចុប្បន្ន គឺមានមិនគ្រប់គ្រាន់ទេដើម្បីធានាថា សមាជិក បុគ្គលិក របស់ស.ប.ព. អនុវត្តន៍តាមក្រមសីលធម៌បានកម្រិតខ្ពស់។

## ៩.៣. តួនាទី

ស.ប.ព.មានសមត្ថភាពទាក់ទងនឹងការទប់ស្កាត់អំពើពុករលួយ។ ជាពិសេសអង្គភាពនេះបានអនុវត្តន៍សកម្មភាពមួយចំនួនទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដូចជាព្រឹត្តិការណ៍ទិវាអន្តរជាតិប្រឆាំងអំពើពុករលួយ នៅថ្ងៃទី០៩ ខែធ្នូ ធ្វើឡើងជារៀងឆ្នាំចាប់តាំងពីឆ្នាំ២០១០មក។

ជាទូទៅអ.ប.ពសកម្មជាបង្គួរក្នុងការអប់រំសាធារណជនអំពីអំពើពុករលួយ និងរបៀបប្រយុទ្ធប្រឆាំងអំពើពុករលួយដោយប្រើប្រាស់មធ្យោបាយដែលខ្លួនមាន។

អ.ប.ព.មានសមត្ថភាពស៊ើបអង្កេតរឿងករណីផ្សេងៗទាក់ទងនឹងអំពើពុករលួយ និងដាក់ទោសលើការប្រព្រឹត្តអំពើពុករលួយ។ ទោះយ៉ាងណាហាក់ដូចជាមានករណីតិចតួច ដែលត្រូវបានស៊ើបអង្កេត ហើយមូលហេតុសម្រាប់ចំពោះសេចក្ដីសម្រេចថាត្រូវស៊ើបអង្កេតយ៉ាងណានោះមានភាពមិនច្បាស់លាស់ទេ។

បើនិយាយតាមផ្លូវច្បាប់អ.ប.ព.មានសមត្ថភាព និងភារកិច្ចទាក់ទងនឹងការស៊ើបអង្កេត។ អង្គភាពនេះមានតួនាទីត្រួតពិនិត្យ និងស៊ើបអង្កេតលើការប្រព្រឹត្តអំពើពុករលួយនៅក្រសួងស្ថាប័នទាំងអស់ ទាំងសាធារណៈ និងឯកជន។

## ៩.៤. អនុសាសន៍

- ធ្វើវិសោធនកម្មមាត្រា៤១ នៃច្បាប់ប្រឆាំងអំពើពុករលួយ ព្រោះច្បាប់នេះអនុញ្ញាតឱ្យដាក់ពន្ធនាគារចំពោះអ្នកផ្ដល់ព័ត៌មានទាក់ទងនឹងអំពើពុករលួយដែលដាក់របាយការណ៍ប្ដឹងអំពីសកម្មភាពពុករលួយ ប្រសិនបើការស៊ើបអង្កេតក្រោយមក ត្រូវបានចាត់ទុកថាជាការស៊ើបអង្កេតឥតប្រយោជន៍។ វិសោធនកម្មមាត្រា៤១នេះគួរតែផ្ទេរការទទួលខុសត្រូវស្វែងរកភស្តុតាង ទៅឱ្យអ.ស.ព.វិញដើម្បីផ្ដល់ភស្តុតាង។
- អ.ប.ព.គួរឱ្យមានជាសាធារណៈនូវរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុ។ របាយការណ៍ទាំងនេះ គួរតែអាចរកបាននៅក្នុងឆ្នាំសារពើពន្ធពាក់ព័ន្ធ។
- វិសោធនកម្មមាត្រា១១ នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយដោយលុបចេញបទប្បញ្ញត្តិដែលចែងថា ប្រធាន និងអនុប្រធានតែងតាំងដោយព្រះរាជក្រឹត្យតាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី។ ដាក់ជំនួសមកវិញថាប្រធាន និងអនុប្រធានគួរត្រូវបានជ្រើសរើសតាមរយៈការប្រកួតប្រជែង។ គណៈកម្មាធិការជ្រើសរើសបុគ្គលិកដែលត្រួតពិនិត្យបេក្ខជនដាក់ពាក្យ និងធ្វើបញ្ជីឈ្មោះបេក្ខជន គួរមានសមាសភាពជាសមាជិកចំនួនស្មើគ្នា មកពីគណបក្សនយោបាយទាំងអស់ដែលមានអាសនៈនៅរដ្ឋសភា។ ■

# ១០ គណបក្សនយោបាយ

## ១០.១. សមត្ថភាព

ក្របខ័ណ្ឌច្បាប់ភាគច្រើន អំណោយផលដល់ការបង្កើត និងដំណើរការគណបក្សនយោបាយ។ សិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ។ លើសពីនេះទៅទៀត ដំណើរការផ្លូវច្បាប់សម្រាប់ការបង្កើតគណបក្សនយោបាយ គឺមានចែងនៅក្នុងច្បាប់ស្តីពីគណបក្សនយោបាយឆ្នាំ១៩៩៧។ ច្បាប់នេះចែងថាក្រុមមួយដែលមានសមាជិកយ៉ាងហោចណាស់ ៨០នាក់ អាយុចាប់ពី១៨ឆ្នាំឡើងទៅ ហើយមានទីលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសកម្ពុជាអាចបង្កើតជាគណបក្សនយោបាយបាន ដោយផ្ញើលិខិតជូនដំណឹងទៅក្រសួងមហាផ្ទៃ។

បន្ទាប់ពីបង្កើតរួចហើយ គណបក្សនយោបាយត្រូវតែចុះបញ្ជីជាផ្លូវការជាមួយក្រសួងមហាផ្ទៃ។ នៅក្នុងដំណាក់កាលនេះគណបក្សត្រូវតែមានសមាជិកយ៉ាងហោចណាស់៤០០០នាក់មកពីខេត្តនិងក្រុងរាជធានីផ្សេងៗ។ នៅពេលចុះបញ្ជីគណបក្សត្រូវតែចែករំលែកលក្ខន្តិកៈរបស់ខ្លួន វិធានផ្ទៃក្នុង ប្រសិនបើមាន និងបញ្ជីរាយនាមសមាជិកជូនទៅឱ្យក្រសួងមហាផ្ទៃ។ គណបក្សនយោបាយក៏ត្រូវបង់ថ្លៃសេវាចុះបញ្ជីផងដែរ។

គណបក្សប្រឆាំងអាចប្រើប្រាស់ធនធានហិរញ្ញវត្ថុមួយចំនួន ប៉ុន្តែធនធានហិរញ្ញវត្ថុទាំងនេះនៅតែទាបឆ្ងាយជាងរបស់គណបក្សគ្រប់គ្រងប្រទេស។ ការប្រកួតប្រជែងនយោបាយមានភាពលម្អៀងទៅខាងរកគណបក្សគ្រប់គ្រងប្រទេស។

គណបក្សនយោបាយត្រូវបានច្បាប់ការពារមិនឱ្យមានការហាមឃាត់ពីអាជ្ញាធរ យោងតាមមាត្រា៣ ៤ នៃច្បាប់ស្តីពីគណបក្សនយោបាយចែងថា គ្មានសមត្ថកិច្ចណាមានសិទ្ធិរំលាយគណបក្សនយោបាយបានឡើយ។ អាចរំលាយបានលើកលែងតែករណីតែមួយគត់គឺ ប្រសិនបើគណបក្សត្រូវបានប្រកាសថាក្ស័យធន ដោយសាលក្រមរបស់តុលាការ។

មានភាពខុសគ្នាតិចតួចរវាងរដ្ឋាភិបាល និងគណបក្សគ្រប់គ្រងប្រទេស។ ភាពជាប់ពាក់ព័ន្ធគ្នារវាងរបស់គណបក្សប្រជាជនកម្ពុជា និងរដ្ឋាភិបាលក៏ជ្រៀតជ្រែកទៅក្នុងសកម្មភាពរបស់គណបក្សប្រឆាំងផ្សេងៗដែរ។

## ១០.២. អភិបាលកិច្ច

គណបក្សនយោបាយត្រូវបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជារៀងរាល់ឆ្នាំ ប៉ុន្តែគ្មានបទបញ្ញាណាដែលតម្រូវថាព័ត៌មាននេះត្រូវមានជាសាធារណៈឡើយ។ គណបក្សនយោបាយជាប់កាតព្វកិច្ចផ្លូវច្បាប់ត្រូវបញ្ជូនរបាយការណ៍ជាទៀងទាត់ស្តីពីសកម្មភាព និងការចំណាយរបស់ខ្លួន។

មានបទប្បញ្ញត្តិច្បាប់មួយចំនួនដែលធានាថា គណបក្សនយោបាយមានហិរញ្ញវត្ថុ និងការចំណាយប្រកបដោយគណនេយ្យភាព ប៉ុន្តែច្បាប់ទាំងនេះមានលក្ខណៈមិនគ្រប់ជ្រុងជ្រោយ។

## ១០.៣. តួនាទី

ប្រព័ន្ធគណបក្សនយោបាយមានប្រសិទ្ធភាពក្នុងការប្រមូលផ្តុំ និងតំណាងផលប្រយោជន៍សង្គមមួយចំនួននៅក្នុងប្រទេស ក៏ប៉ុន្តែមានក្រុមសង្គមសំខាន់ផ្សេងៗដែលត្រូវបានផាត់ចេញ ដោយ

មិនមានតំណាងនៅក្នុងគណបក្សនយោបាយផងដែរ។

ប្រទេសកម្ពុជាមានគណបក្សនយោបាយមួយចំនួនតូចដែលមានស្ថិរភាព និងមានកម្មវិធីផ្សេងៗគ្នាដែលគួរឱ្យកត់សម្គាល់ជាងគេនោះគឺគណបក្សប្រជាជនកម្ពុជា ដែលកំពុងគ្រប់គ្រងប្រទេស និងគណបក្សសង្គ្រោះជាតិដែលជាគណបក្សប្រឆាំងដ៏សំខាន់។

គណបក្សប្រជាជនកម្ពុជាទទួលខុសត្រូវចំពោះសង្គមទាំងមូលក្នុងកម្រិតមួយ។ ចំណុចនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការរីកចម្រើនដែលកម្ពុជាទទួលបាននៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

គណបក្សសង្គ្រោះជាតិដែលជាគណបក្សប្រឆាំងផ្សព្វផ្សាយទស្សនវិស័យសង្គមប្រជាធិបតេយ្យ ដោយសង្កត់ធ្ងន់លើសេវាសុខភាពសាធារណៈ និងសេវាអប់រំដោយបង្កើតគម្រោងចូលនិវត្តន៍សាធារណៈ និងផ្សព្វផ្សាយអំពីគម្រោងសម្បទានដីសេដ្ឋកិច្ច។

## ១០.៤. អនុសាសន៍

- ពង្រឹងនូវបំរាម ហាមមិនឱ្យមន្ត្រីសាធារណៈប្រើប្រាស់ធនធានរដ្ឋសម្រាប់យុទ្ធនាការឃោសនានយោបាយ ដូចមានចែងនៅក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។
- គណបក្សនយោបាយទាំងអស់រួមទាំងគណបក្សគ្រប់គ្រងប្រទេសផង គួរតែចុះហត្ថលេខាលើកិច្ចសន្យាសុចរិតភាព និងលើកកម្ពស់ការប្តេជ្ញាចិត្តដែលខ្លួនបានប្រកាសថាប្រឆាំងអំពើពុករលួយ។
- ការរើសអើងក្នុងរូបភាពណាមួយក៏ដោយគួរហាមឃាត់មិនឱ្យមាននៅក្នុងយុទ្ធនាការនយោបាយ និងសេចក្តីថ្លែងការណ៍ជាសាធារណៈដែលធ្វើឡើងដោយសមាជិកគណបក្សនយោបាយ និងអ្នកកាន់តំណែងសាធារណៈ។ ■

# ១១ ប្រព័ន្ធផ្សព្វផ្សាយ

## ១១.១. សមត្ថភាព

ថ្វីបើក្របខ័ណ្ឌច្បាប់ អនុញ្ញាតឱ្យមានការបង្កើត និងដំណើរការស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ ក៏ប៉ុន្តែនីតិវិធីចុះបញ្ជីមិនបានទប់ស្កាត់ការត្រួតត្រារបស់រដ្ឋាភិបាលលើប្រព័ន្ធផ្សព្វផ្សាយឡើយ។

រដ្ឋធម្មនុញ្ញធានាឱ្យមានសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន។ ច្បាប់រដ្ឋធម្មនុញ្ញនេះស្របតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨ មាត្រា១៩ ចែងថា មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។

ទោះបីជាមានប្រភពប្រព័ន្ធផ្សព្វផ្សាយសំបូរបែបយ៉ាងណាក៏ដោយ ក៏ប្រភពភាគច្រើនត្រូវបានគ្រប់គ្រងផ្តាច់មុខដោយគណបក្សគ្រប់គ្រងប្រទេស ដូចនេះរាល់ទស្សនៈនយោបាយ និងព័ត៌មានដែលសង្គមចាប់អារម្មណ៍ មិនបានផ្សព្វផ្សាយទូលំទូលាយទេ។

ក្រៅពីការពារសេរីភាពក្នុងការសម្តែងមតិ និងសេរីភាពសារព័ត៌មាន មានច្បាប់ការពារមួយចំនួនតូចទប់ស្កាត់ការជ្រៀតជ្រែកមិនសមស្របពីខាងក្រៅ ទៅលើសកម្មភាពការងាររបស់ប្រព័ន្ធផ្សព្វផ្សាយ។

ការត្រួតពិនិត្យដោយចំហមុនពេលចេញផ្សាយទៅលើប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ហាក់ដូចជាពុំមានកើតឡើងជាទូទៅទេ ហើយការត្រួតពិនិត្យមុនពេលចេញផ្សាយតាមអ៊ីនធើណេតមានកម្រិតទាបបើប្រៀបធៀបនឹងប្រទេសជិតខាង។ ម្យ៉ាងទៀតគណបក្សគ្រប់គ្រងប្រទេសគ្រប់គ្រងផ្តាច់មុខលើប្រព័ន្ធផ្សព្វផ្សាយភាគច្រើន។ ដូច្នេះធ្វើឱ្យឯករាជ្យភាពរបស់ប្រព័ន្ធផ្សព្វផ្សាយ នៅក្នុងការអនុវត្តជាក់ស្តែងនៅមានកម្រិត។

## ១១.២. អភិបាលកិច្ច

មានបទប្បញ្ញត្តិតិចតួចណាស់នៅក្នុងវិស័យសារព័ត៌មានដែលស្វះស្វែងឱ្យមានតម្លាភាពទាក់ទងនឹងសកម្មភាពនានារបស់ប្រព័ន្ធផ្សព្វផ្សាយ។ ទោះយ៉ាងណាស្ថាប័នប្រព័ន្ធផ្សព្វផ្សាយមួយចំនួនមានវិធាននិងក្រមសីលធម៌រៀងៗខ្លួនដូចជាបទបញ្ញាផ្ទៃក្នុង ទាក់ទងនឹងគោលនយោបាយ ស្តីពីការធ្វើសេចក្តីរាយការណ៍ពត៌មានជាដើម។

ច្បាប់ស្តីពីសារព័ត៌មានមាត្រា៩ តម្រូវឱ្យបង្ហាញអត្តសញ្ញាណនិយោជក ឬនិពន្ធនាយករបស់ស្ថាប័នទៅក្រសួងព័ត៌មាន។

ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ មិនផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីសកម្មភាពការងាររបស់ខ្លួនទេ។ ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមួយចំនួនតូចមានភាពបើកទូលាយច្រើន ក្នុងការផ្តល់ព័ត៌មានលម្អិតស្តីពីម្ចាស់ស្ថាប័ន និងរចនាសម្ព័ន្ធបុគ្គលិកផ្ទៃក្នុងរបស់ខ្លួននៅលើគេហទំព័រ។

កម្ពុជាពុំមានអ្វីមួយដែលដើរតួនាទីដូចជាក្រុមប្រឹក្សាសារព័ត៌មាន ដើម្បីធានាថាក្រមសីលធម៌អ្នកសារព័ត៌មានត្រូវបានប្រកាន់ខ្ជាប់ និងគោរពតាមនោះទេ។ ប្រទេសកម្ពុជាខ្វះអាជ្ញាធរនិយ័តកម្មមួយសម្រាប់ប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស ព្រមទាំងខ្វះច្បាប់ស្តីពីប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាសផងដែរ ដើម្បីគ្រប់គ្រងផ្នែកវិជ្ជាជីវៈលើអង្គភាពផ្សព្វផ្សាយនានា។

គ្មានក្រមសីលធម៌សម្រាប់វិស័យនេះទាំងមូលទេ។ ទោះយ៉ាងណា ច្បាប់ស្តីពីរបបសារព័ត៌មាន ចែងថាសមាគមអ្នកសារព័ត៌មាននីមួយៗ

ត្រូវបង្កើតក្រមសីលធម៌រៀងៗខ្លួន ដើម្បីអនុវត្តន៍គោលការណ៍មួយចំនួននៅក្នុងវិស័យនេះ។ គោលការណ៍ទាំងនេះរួមមានការគោរពសិទ្ធិឯកជនរបស់បុគ្គល និងសារៈសំខាន់នៃការរក្សាសុចរិតភាពឱ្យបានខ្ពស់ដោយធ្វើការរាយការណ៍តែការពិតដែលមានប្រភពច្បាស់លាស់។

មានវិធានតិចតួច ដើម្បីធានាថានិយោជិតប្រព័ន្ធផ្សព្វផ្សាយមានសុចរិតភាព។ យន្តការដែលមានស្រាប់រួមមានដូចជាការបណ្តុះបណ្តាលបុគ្គលិកអំពីក្រមសីលធម៌នោះជាដើម។

## ១១.៣. តួនាទី

ប្រព័ន្ធផ្សព្វផ្សាយកម្រធ្វើការស៊ើបអង្កេត និងលាតត្រដាងករណីអំពើពុករលួយណាស់។ នៅប្រទេសកម្ពុជាគ្មានស្ថាប័នផ្សព្វផ្សាយជាក់លាក់ណាមួយដែលយកចិត្តទុកដាក់លើវិជ្ជាជីវៈសារព័ត៌មានស៊ើបអង្កេតឡើយ ហើយការងារនេះមិនមែនជាផ្នែកមួយនៃភារកិច្ចសំខាន់ៗរបស់ស្ថាប័នផ្សព្វផ្សាយដែរ។

ស្ថាប័នផ្សព្វផ្សាយយកចិត្តទុកដាក់ខ្លះដែរក្នុងការផ្សព្វផ្សាយដល់សាធារណជន អំពីអំពើពុករលួយ និងផលប៉ះពាល់នៃអំពើពុករលួយ។ ប៉ុន្តែសេចក្តីរាយការណ៍ប្រភេទនេះ មានចំនួនកំណត់តែនៅតាមស្ថាប័នផ្សាយឯករាជ្យមួយចំនួនតូចប៉ុណ្ណោះ។ ស្ថាប័នផ្សព្វផ្សាយឯករាជ្យមួយចំនួនតូច ផ្តោតការយកចិត្តទុកដាក់លើការផ្សព្វផ្សាយព័ត៌មានដល់សាធារណជនអំពីបញ្ហាអភិបាលកិច្ច ប៉ុន្តែស្ថាប័នផ្សព្វផ្សាយភាគច្រើនផ្សាយព័ត៌មានខ្វះគុណភាពជាញឹកញាប់ផ្តើមចេញពីទស្សនវិស័យលម្អៀង។

## ១១.៤. អនុសាសន៍

- ក្រសួងព័ត៌មាន ស្ថាប័នផ្សព្វផ្សាយ និងសង្គមស៊ីវិលពាក់ព័ន្ធ គួរតែធ្វើការរួមគ្នាដើម្បីធ្វើសេចក្តីព្រាងក្រមប្រតិបត្តិការងារនិងក្រមសីលធម៌ថ្មី ដែលនឹងអនុវត្តន៍ទៅលើគ្រប់អ្នកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា។
- រៀបចំបង្កើតក្រុមប្រឹក្សាសារព័ត៌មាន ដើម្បីធ្វើសវនាការ និងស៊ើបអង្កេតលើពាក្យបណ្តឹងផ្សេងៗទាក់ទងនឹងសកម្មភាពរបស់ប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសកម្ពុជា។
- រដ្ឋាភិបាលគួរពិនិត្យឡើងវិញនូវមូលដ្ឋានច្បាប់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ដូចជាទូរទស្សន៍ជាតិកម្ពុជា និងវិទ្យុជាតិកម្ពុជា ដែលប្រតិបត្តិការក្រោមមូលនិធិរបស់រដ្ឋហើយកែសម្រួលយ៉ាងណាឱ្យស្ថាប័នទាំងនេះក្លាយទៅជារបស់ពលរដ្ឋគ្រប់គ្នា និងបម្រើផលប្រយោជន៍ សាធារណៈពិតៗ ពោលគឺមិនមែនជារបស់រដ្ឋាភិបាលតែម្នាក់ឯងទេ។ ■

# ១២ សង្គមស៊ីវិល

## ១២.១. សមត្ថភាព

ទោះបីជាមានបទប្បញ្ញត្តិមួយចំនួន ដែលធានាឱ្យមានបរិយាកាសអំណោយផលដល់សង្គមស៊ីវិលក៏ដោយ ក៏នៅតែមានការរិតត្បិតជាច្រើនដែលអាចរាំងស្ទះដល់សកម្មភាពរបស់អង្គការសង្គមស៊ីវិល។

ក្របខ័ណ្ឌច្បាប់អនុញ្ញាតឱ្យមានការបង្កើតអង្គការសង្គមស៊ីវិល។ ឧទាហរណ៍ រដ្ឋធម្មនុញ្ញធានាឲ្យមានសិទ្ធិបង្កើតសមាគម។

ជាទូទៅអង្គការសង្គមស៊ីវិលមានធនធានគ្រប់គ្រាន់ក្នុងការអនុវត្តសកម្មភាពរបស់ខ្លួន ប៉ុន្តែកង្វះខាតតិចតួចអាចរាំងស្ទះដល់ប្រសិទ្ធភាពការងាររបស់អង្គការសង្គមស៊ីវិល។

ក្របខ័ណ្ឌច្បាប់អនុញ្ញាតឱ្យពលរដ្ឋកម្ពុជាបង្កើតជាក្រុម និងចូលរួមជាក្រុម ដោយមិនគិតពីមនោគមវិជ្ជានយោបាយ សាសនា ឬវត្ថុបំណងឡើយ។ ចំណុចនេះមានចែងនៅក្នុងរដ្ឋធម្មនុញ្ញត្រង់មាត្រា៤១ ដែលចែងថា ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ។

សកម្មជនអង្គការសង្គមស៊ីវិល និងអង្គការដែលធ្វើការលើបញ្ហាដែលមានវិវាទខ្លាំង បានទទួលរងការជ្រៀតជ្រែកមិនសមស្របត្រឹមត្រូវពីរដ្ឋាភិបាល។

## ១២.២. អភិបាលកិច្ច

ជាទូទៅ អង្គការសង្គមស៊ីវិលផ្តល់ព័ត៌មានជាសាធារណៈអំពីសកម្មភាពរបស់ខ្លួន ប៉ុន្តែការផ្សាយព័ត៌មានអំពីការចំណាយហិរញ្ញវត្ថុរបស់ខ្លួន នៅមានកម្រិតនៅឡើយ។ ទិន្នន័យ អំពីការស្ទង់របស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ឆ្នាំ២០១១ បានឱ្យដឹងថា ក្នុងចំណោមចំនួន៣០៩ ដែលបានឆ្លើយនឹងសំណួរ គឺមានអង្គការភាគច្រើនលើសលុប ប្រមាណ៨៨ភាគរយបានផ្តល់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។

ជារួមក្រុមប្រឹក្សាភិបាលរបស់អង្គការសង្គមស៊ីវិល គ្រាន់តែមានប្រសិទ្ធភាពមួយផ្នែក ក្នុងការត្រួតពិនិត្យកំហុសឆ្គងនៅក្នុងសេចក្តីសម្រេចរបស់អង្គការសង្គមស៊ីវិល។ មានសេចក្តីរាយការណ៍ថាក្រុមប្រឹក្សាភិបាលមិនមានភាពជាប់លាប់រហូត និងប្រសិទ្ធភាពក្នុងការផ្តល់យុទ្ធសាស្ត្រ និងវាយតម្លៃអំពីរបៀបដែលកម្មវិធីកំពុងដំណើរការ ឬអនុម័តរបាយការណ៍និងថវិកាឡើយ។

## ១២.៣. តួនាទី

អង្គការសង្គមស៊ីវិលសកម្មក្នុងកម្រិតបង្គួរដែរ ក្នុងការស្វះស្វែងឱ្យរដ្ឋាភិបាលទទួលខុសត្រូវក្នុងសកម្មភាពរបស់ខ្លួន បើទោះបីជាកន្លងមកដល់ពេលនេះ ប្រសិទ្ធភាពនៅមានការរីកចម្រើនសន្សឹមៗក៏ដោយ។

ថ្វីបើជាមុខងារជាអ្នកឃ្លាំមើលជាសាធារណៈរបស់សង្គមស៊ីវិល ត្រូវបានដាក់បញ្ចូលទៅក្នុងរបៀបវារៈអភិវឌ្ឍន៍របស់ប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមកហើយក៏ដោយក៏មានតែអង្គការមួយចំនួនតូចប៉ុណ្ណោះ ដែលចូលរួមក្នុងគណនេយ្យភាពសង្គម។

អង្គការសង្គមស៊ីវិលជាច្រើនចូលរួមពិភាក្សាអំពីកំណែទម្រង់គោលនយោបាយដែលមានគោលបំណងពង្រឹងសុចរិតភាព និងតម្លាភាព

របស់ប្រព័ន្ធអភិបាលកិច្ច បើទោះបីជាការរីកចម្រើនមានសភាពម្តងបន្តិចៗក្តី។

## ១២.៤. អនុសាសន៍

- អង្គការសង្គមស៊ីវិល គួរដឹកនាំដោយធ្វើជាគម្រូគេ ដោយលើកកម្ពស់នូវការអនុវត្តល្អនៅក្នុងការរៀបចំរបាយការណ៍ឱ្យមានតម្លាភាព តាមរយៈការធ្វើរបាយការណ៍ប្រចាំឆ្នាំដែលរៀបរាប់លម្អិតអំពីសកម្មភាព និងហិរញ្ញវត្ថុរបស់ខ្លួន។ របាយការណ៍ទាំងនេះគួរផ្សព្វផ្សាយជាសាធារណៈ នៅក្នុងឆ្នាំសារពើពន្ធបន្ទាប់។
- លើកទឹកចិត្តអង្គការសង្គមស៊ីវិលឱ្យចុះហត្ថលេខា និងប្រកាន់យកគោលការណ៍ក្រមសីលធម៌ និងស្តង់ដារអប្បបរមាសម្រាប់អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ដើម្បីលើកកម្ពស់សុចរិតភាព និងការអនុវត្តប្រកបដោយវិជ្ជាជីវៈនៅក្នុងវិស័យនេះទាំងមូល។ ■

# ១៣ វិស័យអាជីវកម្ម

## ១៣.១. សមត្ថភាព

ក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ផ្តល់ឱ្យមានបរិយាកាសអំណោយផលសម្រាប់ការបង្កើតនិងការធ្វើអាជីវកម្មឯកជននៅក្នុងប្រទេសកម្ពុជា។ ច្បាប់ផ្សេងៗត្រូវបានអនុម័តជាបន្តបន្ទាប់ ដើម្បីធានាឱ្យមានបរិយាកាសអាជីវកម្មប្រកបដោយសុវត្ថិភាព។

ដើម្បីបង្កើត និងដំណើរការក្រុមហ៊ុនអាជីវកម្មមួយ ត្រូវចំណាយច្រើនណាស់ ទាក់ទងនឹងពេលវេលា និងនីតិវិធីការិយាធិបតេយ្យ ហើយក៏តម្រូវឱ្យមានការវិនិយោគប្រាក់កាសលុយកាក់ច្រើនគួរសម។ ច្បាប់ការពារនៅមានកម្រិតនៅឡើយ ដើម្បីទប់ស្កាត់ការជ្រៀតជ្រែតមិនសមហេតុផលពីខាងក្រៅ នៅក្នុងសកម្មភាពរបស់អាជីវកម្មឯកជន។

ឯករាជ្យភាពរបស់វិស័យអាជីវកម្ម នៅមានកម្រិតគួរឱ្យកត់សម្គាល់ ដោយសារតែអំពើបក្សពួកនិយមកម្រិតខ្ពស់នៅក្នុងប្រព័ន្ធខ្សែបក្សពួកនិយមបរិបាលកិច្ចរបស់គណបក្សគ្រប់គ្រងប្រទេស ក៏ដូចជាការផ្តល់សំណូកជាទូទៅ ឱ្យទៅមន្ត្រីសាធារណៈសម្រាប់សេវាដែលត្រូវការចាំបាច់។

## ១៣.២. អភិបាលកិច្ច

មានបទប្បញ្ញត្តិ និងស្ថាប័នមួយចំនួនដែលធានាឱ្យមានតម្លាភាពនៅក្នុងសកម្មភាពអាជីវកម្ម ប៉ុន្តែនៅតែមានចំណុចខ្វះខាតមួយចំនួន។ ថ្វីបើអាជីវកម្ម ពិតជាបានបើកចំហលាតត្រដាងព័ត៌មានពាក់ព័ន្ធមួយចំនួន អំពីការចាត់ចែង និងសកម្មភាពរបស់ខ្លួន ប៉ុន្តែជារឿយៗ មានព័ត៌មានមិនពេញលេញ។

អភិបាលកិច្ចនៅតាមក្នុងក្រុមហ៊ុន មានប្រសិទ្ធភាពក្នុងកម្រិតមួយចំនួន ដោយអភិបាលកិច្ចទទួលបានកិច្ចការពារតាមរយៈស្ថាប័នត្រួតពិនិត្យ។ ទោះយ៉ាងណា ក៏អភិបាលកិច្ចនេះមាននៅក្នុងប្រព័ន្ធមួយដែលមិនមានការអនុវត្តនីតិរដ្ឋរឹងមាំហើយបទប្បញ្ញត្តិទាំងឡាយ ពុំទាក់ទងនឹងអភិបាលកិច្ចក្រុមហ៊ុន ក៏ពុំមានការធានាជាក់លាក់នៅក្នុងការអនុវត្តជាក់ស្តែង។

មិនមានយន្តការគ្រប់គ្រាន់សម្រាប់ធានាឱ្យមានសុចរិតភាពក្នុងចំណោមអ្នកដែលបំពេញការងារនៅក្នុងវិស័យអាជីវកម្មទេ អាស្រ័យដោយការស្វែងរកសំណូកនិងការទទួលសំណូកនៅក្នុងវិស័យអាជីវកម្មមានកម្រិតខ្ពស់ ហើយការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយក៏នៅមានកម្រិត។

## ១៣.៣. តួនាទី

សកម្មភាពរបស់វិស័យអាជីវកម្មក្នុងការដែលធ្វើឱ្យរដ្ឋាភិបាលចូលរួមចំណែកក្នុងការប្រឆាំងអំពើពុករលួយ នៅមានកម្រិតនៅឡើយ។

វេទិការដ្ឋាភិបាល-វិស័យឯកជន តែងធ្វើការជួបប្រជុំជាទៀងទាត់ ដើម្បីពិភាក្សាបញ្ហាគោលនយោបាយរយៈពេលវែង ក៏ដូចជាប្រតិបត្តិការប្រចាំថ្ងៃ ដោយផ្តល់ជាឱកាសសម្រាប់ការពិគ្រោះយោបល់មួយ ដែលនៅក្នុងការពិគ្រោះយោបល់នេះ តំណាងក្រុមហ៊ុនអាជីវកម្ម និងរដ្ឋាភិបាលអាចជួបប្រជុំគ្នាដើម្បីពិភាក្សា និងដោះស្រាយបញ្ហានានាដែលកើតចេញមកពីសកម្មភាពអាជីវកម្ម។

នៅក្នុងវេទិកានេះអំពើពុករលួយត្រូវបានលើកឡើងថាជាក្តីកង្វល់មួយ។

## ១៣.៤. អនុសាសន៍

- រដ្ឋាភិបាល អង្គភាពប្រឆាំងអំពើពុករលួយ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរធ្វើការរួមគ្នាដើម្បីធ្វើឱ្យមានបរិយាកាសមួយដែលនៅក្នុងនោះ អាជីវកម្មស្អាតស្អំទទួលបានការលើកទឹកចិត្ត។
- ចុះហត្ថលេខាលើគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្មយករ៉ែ។ ជាងនេះទៀត គួរអនុវត្តន៍យន្តការដើម្បីពិនិត្យតាមដានយ៉ាងប្រុងប្រយ័ត្ននិងកំណត់បទបញ្ញាលើឧស្សាហកម្ម និស្សារណកម្មយករ៉ែ និងប្រេងកាតរបស់កម្ពុជា ដោយធានាថា ធនធានត្រូវបានគ្រប់គ្រងប្រកបដោយចីរភាពដើម្បីកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ប្រទេសនៅពេលអនាគត។ ■

# សេចក្ដីសន្និដ្ឋាន

ប្រទេសកម្ពុជា អាចត្រូវបានចាត់ទុកថាជាប្រទេសមួយដែលមានប្រព័ន្ធសុចរិតភាពថ្នាក់ជាតិខ្សោយ។ ការសិក្សានេះបង្ហាញថា ស្ថាប័នតុលាការ គឺជាស្ថាប័នដែលខ្សោយជាងគេ បន្ទាប់មកគឺទីភ្នាក់ងារអនុវត្តន៍ច្បាប់។ ស្ថាប័នដែលរឹងមាំជាងគេ គឺសង្គមស៊ីវិល បន្ទាប់មក គឺអង្គនីតិប្រតិបត្តិ និងគណបក្សនយោបាយ។ ស្ថាប័នទាំងបីនេះ មានចំណាត់ថ្នាក់មធ្យម ដែលនេះបង្ហាញថា ទោះបីជាស្ថាប័នទាំងបីមានសមាសធាតុខ្លាំងមួយចំនួនក្ដី ក៏ចាំបាច់ត្រូវតែពង្រឹងបទប្បញ្ញត្តិនានាដើម្បីធានាថា ស្ថាប័នទាំងបី ប្រព្រឹត្តទៅប្រកបដោយក្រមសីលធម៌ មានឯករាជ្យភាព និងមានគណនេយ្យភាព។ ស្ថាប័ន/វិស័យភាគច្រើន ស្ថិតនៅក្នុងចំណាត់ថ្នាក់ខ្សោយ។ នៅក្នុងប្រព័ន្ធសុចរិតភាពថ្នាក់ជាតិទាំងមូល គេឃើញមានគម្លាតគួរឲ្យកត់សម្គាល់រវាងច្បាប់ និងការអនុវត្តជាក់ស្ដែង។ ទោះបីជាច្បាប់អាចមានគ្រប់ជ្រុងជ្រោយជាបង្គួរក្ដីក៏ច្បាប់ទាំងនោះមិនទាន់បានលើកកម្ពស់ឲ្យមានប្រសិទ្ធភាព ឬអនុវត្តន៍ឲ្យបានស្មើភាពនៅឡើយ។

ទោះបីជាភាពរឹងមាំរបស់ប្រព័ន្ធនេះជារួមនៅមានកម្រិតក្ដី ក៏គេសង្កេតឃើញមានផ្នែកមួយចំនួនកំពុងតែផ្លាស់ប្ដូរទៅរកភាពល្អប្រសើរ។ ចាប់តាំងពីការវាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិនៅកម្ពុជា ត្រូវបានធ្វើជាលើកដំបូងនៅក្នុងឆ្នាំ ២០០៦ មក ច្បាប់ប្រឆាំងអំពើពុករលួយត្រូវបានអនុម័ត ហើយអង្គភាពប្រឆាំងអំពើពុករលួយក៏បានបង្កើតឡើងផងដែរ។ ករណីមួយចំនួនពាក់ព័ន្ធទៅនឹងការសូកប៉ាន់ ក្លែងបន្លំ និងការជំរិតទារប្រាក់ ត្រូវបាននាំយកទៅកាត់ទោស។ កិច្ចប្រឹងប្រែងធ្វើវិមជ្ឈការ និងវិសហមជ្ឈការលើវិស័យសាធារណៈ បានជួយឲ្យការអនុវត្តអភិបាលកិច្ចប្រកបដោយតម្លាភាព និងគណនេយ្យភាព មានការរីកចម្រើននៅថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងនេះក្ដី នៅមានបញ្ហាធំៗមួយចំនួន ដែលជាឧបសគ្គរាំងមិនឲ្យទទួលបានទាំងស្រុង នូវប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។

នៅក្នុងប្រទេសមួយដែលកំពុងមានការអភិវឌ្ឍឆាប់រហ័ស ប្រព័ន្ធអភិបាលកិច្ចក៏ត្រូវតែមានការផ្លាស់ប្ដូរផងដែរ ដើម្បីធានាថាប្រទេសនោះបានបំពេញតាមសេចក្ដីត្រូវការរបស់ប្រជាជនខ្លួន។ រដ្ឋាភិបាលត្រូវតែតំណាងឲ្យសម្លេងពលរដ្ឋ ឲ្យបានកាន់តែច្រើនជាងមុន ដោយរួមបញ្ចូលទាំងក្រុមជនជាតិភាគតិចផងដែរ។ រដ្ឋាភិបាលត្រូវតែផ្ដល់សេវាកម្មឲ្យបានគ្រប់គ្រាន់ និងធានាឲ្យមានកិច្ចការពារសិទ្ធិសម្រាប់ពលរដ្ឋទាំងអស់នៅក្នុងប្រទេសកម្ពុជា។

អនុសាសន៍ដែលបានផ្ដល់ជូននៅក្នុងរបាយការណ៍នេះ គឺជាការជួយបំពេញបន្ថែមពីលើក្របខ័ណ្ឌដែលមានស្រាប់នៅពេលបច្ចុប្បន្ន សម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា។ អនុសាសន៍ទាំងនេះ ផ្ដល់ជាកម្លាំងជំរុញបន្ថែម និងជាទិសដៅបន្ថែមទៀតសម្រាប់កិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រ រវាងភាគីពាក់ព័ន្ធផ្នែកអភិបាលកិច្ចទាំងអស់ ដើម្បីសម្រេចបាននូវសមភាព និងយុត្តិធម៌ឲ្យបានកាន់តែថែមច្រើន និងដើម្បីកាត់បន្ថយអំពើពុករលួយ។ ដោយផ្ដល់អាទិភាពទៅលើកំណែទម្រង់ប្រព័ន្ធតុលាការ និងការបង្កើនសិទ្ធិទទួលព័ត៌មានឲ្យបានកាន់ទូលំទូលាយ នោះចំណុចខ្សោយទាំងប៉ុន្មានដែលបានគូសបញ្ជាក់នៅក្នុងប្រព័ន្ធសុចរិតភាពថ្នាក់ជាតិទាំងមូល នឹងអាចចាប់ផ្ដើមដោះស្រាយបាន។ ■

របាយការណ៍ស្តីពី*ការវាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិប្រទេសកម្ពុជា* ធ្វើការវាយតម្លៃទៅលើស្ថានភាពប្រព័ន្ធអភិបាលកិច្ចរបស់ប្រទេសកម្ពុជា។ របាយការណ៍នេះវាយតម្លៃស្ថាប័នចំនួន ១៣ រាប់តាំងពីស្ថាប័នតុលាការ អង្គភាពប្រឆាំងអំពើពុករលួយ រហូតដល់សង្គមស៊ីវិល។ ប្រព័ន្ធសុចរិតភាពថ្នាក់ជាតិ ដែលដំណើរការបានល្អ គឺជួយការពារប្រឆាំងនឹងអំពើពុករលួយ ហើយចូលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងកាន់តែខ្លាំងក្លាក្នុងការប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានអំណាច។ អំពើពុករលួយធ្វើឱ្យប៉ះពាល់ដល់អភិបាលកិច្ចល្អ នីតិរដ្ឋ និងសិទ្ធិមនុស្សជាមូលដ្ឋាន។ អំពើពុករលួយនាំឱ្យមានការប្រើប្រាស់ធនធានមិនត្រឹមត្រូវ បោកបន្លំប្រជាពលរដ្ឋ បង្កអន្តរាយដល់វិស័យឯកជន និងបន្លំទីផ្សារហិរញ្ញវត្ថុ។ ប៉ុន្តែ ប្រសិនបើ ស្ថាប័នអភិបាលកិច្ច ត្រូវបានគ្រប់គ្រងដោយបទបញ្ញាត្រឹមត្រូវ និងឥរិយាបទប្រកបដោយគណនេយ្យភាព នោះអំពើពុករលួយ មិនសូវជាទំនងនឹងកើតឡើងច្រើនទេ។ អង្គការតម្លាភាពកម្ពុជា បានបង្កើតអនុសាសន៍គោលនយោបាយគន្លឹះៗ ដោយផ្អែកលើមូលដ្ឋាននៃការរកឃើញនានាពីរបាយការណ៍វាយតម្លៃនេះ។ អនុសាសន៍ដែលមាននៅក្នុងរបាយការណ៍នេះ ស្វះស្វែងស្នើឲ្យមានការចូលរួមពីរដ្ឋាភិបាល ម្ចាស់ជំនួយ និងសង្គមស៊ីវិល ដើម្បីជំរុញឱ្យមានកំណែទម្រង់សំខាន់ៗដើម្បីពង្រឹងប្រព័ន្ធសុចរិតភាព។ ការពង្រឹងប្រព័ន្ធសុចរិតភាពថ្នាក់ជាតិ ជំរុញឱ្យមាន អភិបាលកិច្ចកាន់តែល្អប្រសើរលើគ្រប់ផ្នែកទាំងអស់នៅក្នុងសង្គម ហើយចុងក្រោយបំផុត ជួយចូលរួមចំណែកឲ្យមានសង្គមមួយដែលជាទូទៅ កាន់តែមានភាពយុត្តិធម៌។